# مدرسة اهل البيت

صلوات الله عليهم

# សាលា អាស្ហ់លុល-បៃត៍

## សៀវភៅសិក្សា ប្រវត្តិសាស្រ្ត (تَارِيْخ)

## ថ្នាក់ទី ៤ (អាយុ ៨-៩ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ អាស្ហ់លុល-បៃត៍عليهم السلام - អាអ៊ីម៉ាស្ហ់عليهم السلام - ស្ហ៊ីអាស្ហ់ អ៊ីស្នណា អាស្ហារីយ៉ាស្ហ់ … ៤
មេរៀនទី ២-៣ អាអ៊ីម៉ាស្ហ់عليهم السلام - ព្រះនាមរបស់បិតានិងមាតា … ៧
មេរៀនទី ៤-៥ ថ្ងៃកំណើតនិងស្រុកកំណើតរបស់អាអ៊ីម៉ាស្ហ់ … ៩
មេរៀនទី ៦-៧ ថ្ងៃនិងកន្លែងពលីកម្មរបស់អាអ៊ីម៉ាស្ហ់ … ១២
មេរៀនទី ៨-៩ ឋានន្តររបស់អាអ៊ីម៉ាស្ហ់ … ១៥
មេរៀនទី ១០ រៀនសាឡើងវិញទាំងអស់អំពីអាអ៊ីម៉ាស្ហ់عليهم السلام … ១៧
មេរៀនទី ១១ សៃយីដ្ហាស្ហ់ខ៏ឌីយ៉ាស្ហ់سلام الله عليها … ១៩
មេរៀនទី ១២ សៃយីដ្ហាស្ហ់ ហ្វាទីម៉ាស្ហ់ អាស្ហ-ស្ហាស្ហ់រ៉អ៊ូسلام الله عليها … ២៥
មេរៀនទី ១៣ ព្រះគម្ពីរគួរអានថែងអំពីសៃយីដ្ហាស្ហ់ ហ្វាទីម៉ាស្ហ់ អាស្ហ-ស្ហាស្ហ់រ៉អ៊ូسلام الله عليها … ២៩
មេរៀនទី ១៤ អ៊ីដ្ហទាំងប្រាំ - អារម្ភកថា … ៣៣
មេរៀនទី ១៥ អ៊ីដ្ហ អ៊ុល-យ៉ូមអ៊ាស្ហ់ … ៣៥
មេរៀនទី ១៦ អ៊ីដ្ហ អ៊ុល-ហ៊្គាច់ … ៣៧
មេរៀនទី ១៧ អ៊ីដ្ហ អ៊ុល-ហ្វិត្ហ៍រ … ៤០
មេរៀនទី ១៨ អ៊ីដ្ហ អាល់-ក៏ដៀរ … ៤២
មេរៀនទី ១៩ អ៊ីដ្ហ អាល់-មូបាហាឡាស្ហ់ (المُباهَلَة) … ៤៥
មេរៀនទី ២០ ឈ្មោះខែអ៊ីស្លាម … ៤៨

# មេរៀនទី ១

## អាស់លុល-បៃត៍ﷺ - អាអ៊ីម៉ាស់ﷺ - ស្ហ៊ីអ៊ុស់ អ៊ីស្នាណា អ៊ុស្ហារីយ៉ាស់

## شِيْعَة اِثْنَا عَشَرِيَّة

យើងជាមុស្លីម ស្ហ៊ីអ៊ុស់ អ៊ីស្នាណា អ៊ុស្ហារីយ៉ាស់ ។ តើ មុស្លីម ស្ហ៊ីអ៊ុស់ អ៊ីស្នាណា អ៊ុស្ហារីយ៉ាស់ មានន័យថាអ្វី ? ហេតុអ្វីគេមិនហៅយើងថាត្រឹមតែមុស្លីម ?

ស្ហ៊ីអ៊ុស់មានន័យថាអ្នកតាម ។ អ៊ីស្នាណា អ៊ុស្ហារីយ៉ាស់ មានន័យថា ១២ (គឺ ១២ អ៊ីម៉ាំﷺ) ។

ហេតុដូច្នេះ ពេលថាយើងជាមុស្លីម ស្ហ៊ីអ៊ុស់ អ៊ីស្នាណា អ៊ុស្ហារីយ៉ាស់ យើងបញ្ជាក់ឲ្យម្នាក់ៗដឹងថា យើងជាមុស្លីមដែលអនុវត្តិតាមសិក្ខាបទរបស់ព្រះសាស្ដាﷺនិងបណ្ដាអាស់លុល-បៃត៍ﷺរបស់ព្រះអង្គﷺដែលជាអ៊ីម៉ាំ ១២ អង្គﷺ (គឺតាមព្រះរាជកុលដ្ឋានﷺរបស់ព្រះអង្គﷺ) ។

ទោះបីគោលជំនឿរបស់មុស្លីមទាំងអស់ជាគោលជំនឿតែមួយក៏ដោយ តែមាននិកាយផ្សេងៗក្នុងសាសនាអ៊ីស្លាម (៧២ និកាយ) ។ យើងទាំងអស់គ្នាជឿព្រះﷻតែមួយគត់ យើងទាំងអស់គ្នាជឿថាមូហាំម៉ាដ់ﷺជាព្រះសាស្ដាﷺរបស់ព្រះអង្គﷻ ។ ម៉ាស្ហាប់ (ច្បាប់សាសនា) ខុសគ្នាបន្តិចសម្រាប់និកាយនីមួយៗ ។

ទោះបីនិកាយភាគច្រើនត្រូវរលត់បាត់អស់ក៏ដោយ តែនិកាយដែលនៅសល់ត្រូវចែកជាពីរក្រុមធំ ។ ក្រុមទាំងពីរនេះត្រូវចែកជាក្រុមតូចៗ ។

ក្រុមធំទាំងពីរនេះគឺ៖

១-ក្រុម ស៊ុន្នី - ៨៥% នៃមុស្លីមទាំងអស់ដែលអនុវត្តិតាមសិក្ខាបទរបស់ព្រះសាស្ដាﷺតែមិនជឿអ៊ីម៉ាំទាំង ១២ អង្គﷺទេ ។ ឧទាហរណ៍ និកាយហ្ងាណាហ្វី និកាយហ្ងាន់បាលី និកាយស្ហាហ្វីអ៊ី និកាយម៉ាលីគី ។

២-ក្រុម ស្ហ៊ីអ៊ុស់ - ១៥% នៃមុស្លីមទាំងអស់ដែលអនុវត្តិតាមសិក្ខាបទរបស់ព្រះសាស្ដាﷺនិងអ៊ីម៉ាំទាំង ១២ អង្គﷺ ។ ឧទាហរណ៍ និកាយស្ហ៊ីអ៊ុស់ អ៊ីស្នាណា អ៊ុស្ហារីយ៉ាស់ និកាយស្ហ៊ីអ៊ុស់ ប៊ុះហ្វ៍រ៉ោះត្ហ៍ (بُهْرَة) និកាយស្ហ៊ីអ៊ុស់ អ៊ីសម៉ាអ៊ីលី ។

និកាយមុស្លីមធំជាងគេមួយគត់ក្នុងលោកគឺនិកាយ ស្ហ៊ីអ៊ុស់ អ៊ីស្នាណា

អាលុស្សារីយ៉ាស្ស ។ គេហៅយើងដែរថាយ៉ាកុ់ហ្វារី ព្រោះអ៊ីម៉ាំទី ៦ របស់យើង គឺ អ៊ីម៉ាំ យ៉ាកុ់ហ្វារ អាស្ស-ស្សឌិក صلوات الله عليه والسلام បានបង្ហាត់បង្រៀនយើងច្បាប់ភាគច្រើននៅក្នុង ម៉ាស្ស់ហ្វាប់យើង ។

ព្រះសន្តអាអ៊ីម៉ាស្ស់ عليهم السلام របស់យើងគឺ៖

១-អ៊ីម៉ាំ អាលី صلوات الله عليه والسلام

២-អ៊ីម៉ាំ ហាសាន់ صلوات الله عليه والسلام

៣-អ៊ីម៉ាំ ហ៊ូសៃន៍ صلوات الله عليه والسلام

៤-អ៊ីម៉ាំ អាលី ស៊ែនុល-អាប៊ីឌីន صلوات الله عليه والسلام

៥-អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام

៦-អ៊ីម៉ាំ យ៉ាកុ់ហ្វារ អាស្ស-ស្សឌិក صلوات الله عليه والسلام

៧-អ៊ីម៉ាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام

៨-អ៊ីម៉ាំ អាលី អារ-រីដ៏ صلوات الله عليه والسلام

៩-អ៊ីម៉ាំ មូហាំម៉ាដ់ អាត់-តាគី صلوات الله عليه والسلام

១០-អ៊ីម៉ាំ អាលី អាន់-ណាគី صلوات الله عليه والسلام

១១-អ៊ីម៉ាំ ហាសាន់ អាល់-អាស់ការី صلوات الله عليه والسلام

១២-អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-ម៉ាស្ស់ឌី صلوات الله عليه والسلام ។

# លំហាត់ ១

ស្ទីអ៊ុស្ទុំមានន័យថា៖

ក) មុស្លីម ។

ខ) មិត្ត ។

គ) អ្នកតាម ។

ឃ) ១២

ស្ទីអ៊ុស្ទុំ អ៊ីស្ទ្រណា អ៊ុស្វារីយ៉ាស្ទុំ មានន័យថាអ្វី ?

______________________________________________

____________________

តើគេហៅ ស្ទីអ៊ុស្ទុំ អ៊ីស្ទ្រណា អ៊ុស្វារីយ៉ាស្ទុំ ដែរថាអ្វី ? ហេតុអ្វី ?

______________________________________________

____________________

ក្រុមពីរធំជាងគេក្នុងសាសនាអ៊ីស្លាមគឺក្រុមអ្វី ?

______________________________________________

____________________

និកាយមុស្លីមធំជាងគេមួយគត់ក្នុងលោកគឺនិកាយអ្វី ?

______________________________________________

____________________

# មេរៀនទី ២-៣

## អាអ៊ីម៉ាស់ عليهم السلام - ព្រះនាមរបស់បិតានិងមាតា

| ព្រះបិតារបស់ព្រះសន្តអ៊ីមុាំទាំង ១២ | ព្រះមាតា |
|---|---|
| ១.អ៊ីមុាំអាលី صلوات الله عليه والسلام | សៃយីដាស់ ហ្វាទីម៉ាស់ ប៊ិនទី អាសាដ់ سلام الله عليها |
| ២-អ៊ីមុាំ ហាសាន់ صلوات الله عليه والسلام ៣-អ៊ីមុាំ ហូសែន៍ صلوات الله عليه والسلام | សៃយីដាស់ ហ្វាទីម៉ាស់ អាស់សាស់រ៉អ៊ សلام الله عليها |
| ៤-អ៊ីមុាំ អាលី ស្សែនុល-អាប៊ីឌីន صلوات الله عليه والسلام | សៃយីដាស់ ស្ហាស់រ៉បានូ (شَهْرَبَانُو) |
| ៥-អ៊ីមុាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام | សៃយីដាស់ ហ្វាទីម៉ាស់ ប៊ិនទី អាល់-ហាសាន់ |
| ៦-អ៊ីមុាំ យ៉ាក់ហ្វារ អាស់-ស្វាឌិក صلوات الله عليه والسلام | សៃយីដាស់ ហ្វាទីម៉ាស់ (أم فروة بنت القاسم អ៊ុម ហ្វារវ៉ាស់) |
| ៧-អ៊ីមុាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام | សៃយីដាស់ ហាមីដាស់ (حَميدَة) |
| ៨-អ៊ីមុាំ អាលី អារ-រីដ៏ صلوات الله عليه والسلام | សៃយីដាស់ អ៊ុមុល-បានីន ណាជ់ម៉ាស់ (أُمّ ٱلْبَنِين نجمة) |
| ៩-អ៊ីមុាំ មូហាំម៉ាដ់ អាត់-តាគី صلوات الله عليه والسلام | សៃយីដាស់ សាប៊ីកាស់ ខយ់ស៊ូរ៉ន (سبيكة خَيزُران) |
| ១០-អ៊ីមុាំ អាលី អាន់-ណាគី صلوات الله عليه والسلام | សៃយីដាស់ ស៊ូម៉ាណា |
| ១១-អ៊ីមុាំ ហាសាន់ អាល់-អាស់ការី صلوات الله عليه والسلام | សៃយីដាស់ ស៊ូឡៃល៍ ឬ សៅសាន (سليل و سوسن) |
| ១២-អ៊ីមុាំ មូហាំម៉ាដ់ អាល់-ម៉ាស់ឌី صلوات الله عليه والسلام | សៃយីដាស់ ណារយ៉ើស (نرجس) |

## លំហាត់ ៣

ចូរគូសឈ្មោះអុីមុាំនីមួយៗភ្ជាប់នឹងឈ្មោះរបស់ព្រះមាតា ។

| | |
|---|---|
| ៨-អុីមុាំ អាុលី អារ-រីដ៏ صلوات الله عليه والسلام | សៃយីដាស់ ហ្វាទីម៉ាស់ ប៊ិនទី អាសាដ់ سلام الله عليها |
| ១០-អុីមុាំ អាុលី អាន់-ណាគី صلوات الله عليه والسلام | សៃយីដាស់ អុំមុល-បានីន ណាជ់ម៉ាស់ (أُمّ ٱلْبَنِين نجمة) |
| ៦-អុីមុាំ យ៉ាកុំហ្វារ អាស់-ស្វាឌិក صلوات الله عليه والسلام | សៃយីដាស់ ស្វឡៃល៍ ឬ សៅសាន (سليل و سوسن) |
| ៥-អុីមុាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام | សៃយីដាស់ ហាមីដាស់ (حَميدَة) |
| ១-អុីមុាំអាុលី صلوات الله عليه والسلام | សៃយីដាស់ ណារយ៊ីស (نرجس) |
| ១២-អុីមុាំ មូហាំម៉ាដ់ អាល់-ម៉ាហ្ទី صلوات الله عليه والسلام | សៃយីដាស់ ស្វម៉ាណា |
| ៣-អុីមុាំ ហ៊ូសែន៍ صلوات الله عليه والسلام | សៃយីដាស់ ហ្វាទីម៉ាស់ អាស់ស្វាស់រ៉អុំ سلام الله عليها |
| ៥-អុីមុាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام | សៃយីដាស់ សាប៊ីកាស់ ខយ់ស្វូរ៉ន (سبيكة خَيزُران) |
| ៧-អុីមុាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام | សៃយីដាស់ ស្វាស់រ៉បានូ (شَهْرَبَانُو) |
| ១១-អុីមុាំ ហាសាន់ អាល់-អាស់ការី صلوات الله عليه والسلام | សៃយីដាស់ ហ្វាទីម៉ាស់ ប៊ិនទី អាល់-ហាសាន់ |
| ៩-អុីមុាំ មូហាំម៉ាដ់ អាត់-តាគី صلوات الله عليه والسلام | សៃយីដាស់ ហ្វាទីម៉ាស់ (អុំម ហ្វារវ៉ាស់ أم فروة بنت القاسم) |

# មេរៀនទី ៤-៥

## ថ្ងៃកំណើតនិងស្រុកកំណើតរបស់អាអ៊ីម៉ាស់ عليهم السلام

ថ្ងៃកំណើតរបស់អ៊ីម៉ាំនីមួយ ជាឱកាសរីករាយជាទីបំផុតសម្រាប់យើង ។ វាជាថ្ងៃដែលអល់ឡោះហ៊្ عز وجل ព្រះរាជទានឲ្យយើង នូវអ៊ីម៉ាំអស្ចារ្យមួយអង្គសម្រាប់ដឹកនាំយើង ។

ដូច្នេះរាល់ឆ្នាំ ក្នុងឱកាសបុណ្យខួបកំណើតរបស់អ៊ីម៉ាំនីមួយៗ យើងស្លៀកពាក់ស្អាត យើងទៅម៉ាស់យិដ្ឋ យើងស្តាប់ឃុត្តបាស់ដើម្បីស្គាល់អ៊ីម៉ាំអង្គនេះនិងអ្វីដែលព្រះអង្គបានបង្ហាត់បង្រៀនយើង ដើម្បីយើងនឹងអាចកែខ្លួនឲ្យកាន់តែប្រសើរឡើងបាន ។

បើយើងបណ្តោយឲ្យថ្ងៃអស្ចារ្យនេះកន្លងផុតទៅ ដោយពុំបានសិក្សានិងកែខ្លួនឲ្យកាន់តែល្អឡើងទេនោះ យើងពុំបានអបអរសាទរថ្ងៃបុណ្យខួបកំណើតរបស់អ៊ីម៉ាំអង្គនោះឲ្យសមនឹងគោលបំណងរបស់ព្រះអង្គទេ ។

| អ៊ីម៉ាំ | ថ្ងៃនិងស្រុកកំណើត |
|---|---|
| ១-អ៊ីម៉ាំ អ៊ាលី صلوات الله عليه والسلام | ១៣ រ៉យ៉ាប់ ២៣ ឆ្នាំមុនសករាជហ៊ីចរ៉ោះត៍ នៅម៉ាក់កាស់ |
| ២-អ៊ីម៉ាំ ហ៊ាសាន់ صلوات الله عليه والسلام | ១៥ រ៉ម៉ាដន ឆ្នាំ ៣ សករាជហ៊ីចរ៉ោះត៍ នៅម៉ាឌីណាស់ |
| ៣-អ៊ីម៉ាំ ហ៊ូសៃន៍ صلوات الله عليه والسلام | ៣ ស្ហាក់បាន ឆ្នាំ ៤ សករាជហ៊ីច្ររ៉ោះត៍ នៅម៉ាឌីណាស់ |
| ៤-អ៊ីម៉ាំ អ៊ាលី ស៊ែនុល អ៊ាប៊ីឌីន صلوات الله عليه والسلام | ៥ ស្ហាក់បាន ឆ្នាំ ៣៨ សករាជហ៊ីចរ៉ោះត៍ នៅម៉ាឌីណាស់ |
| ៥-អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាល់-បាក្វៀរ صلوات الله عليه والسلام | ១ រ៉យ៉ាប់ ឆ្នាំ ៥៧ សករាជហ៊ីចរ៉ោះត៍ នៅម៉ាឌីណាស់ |
| ៦-អ៊ីម៉ាំ យ៉ាក់ហ្វារ អាស់-ស្វឌិក្វ صلوات الله عليه والسلام | ១៧ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំ ៨៣ សករាជហ៊ីចរ៉ោះត៍ នៅ ម៉ាឌីណាស់ |

| | |
|---|---|
| ៧-អ៊ីម៉ាំ មូសា អាល់-កាស្ហ៊ីម صلوات الله عليه والسلام | ៧ ស្ហ៍ហ្វារ ឆ្នាំ ១២៨ សករាជហ៊ីជ្ជរ៉ោះត៏ នៅអាប់វ៉ាអ៊ុ |
| ៨-អ៊ីម៉ាំ អាលី អារ-រីដ្ឋ៍ صلوات الله عليه والسلام | ១១ ស៊ុលកាក្កុំដ្ហាស់ ឆ្នាំ ១៤៨ សករាជ ហ៊ីជ្ជរ៉ោះត៏ នៅម៉ាឌីណាស់ |
| ៩-អ៊ីម៉ាំ មូហាំម៉ាដ៏ អាត់-តាគ្ហី صلوات الله عليه والسلام | ១០ រ៉យ៉ាប់ ឆ្នាំ ១៩៥ សករាជហ៊ីជ្ជរ៉ោះត៏ នៅម៉ាឌីណាស់ |
| ១០-អ៊ីម៉ាំ អាលី អាន់-ណាគ្ហី صلوات الله عليه والسلام | ១៥ ស៊ុលហ៊ីជ្ជយ៉ាស់ ឆ្នាំ ២១២ សករាជ ហ៊ីជ្ជរ៉ោះត៏ នៅស៊ូរបាស់ |
| ១១-អ៊ីម៉ាំ ហាសាន់ អាល់-អាស់ការី صلوات الله عليه والسلام | ១០ រ៉ប៊ីអ៊ុល អាខៀរ ឆ្នាំ ២៣២ សករាជ ហ៊ីជ្ជរ៉ោះត៏ នៅម៉ាឌីណាស់ |
| ១២-អ៊ីម៉ាំ មូហាំម៉ាដ៏ អាល់-ម៉ាស្ហ៍ឌី صلوات الله عليه والسلام | ១៥ ស្ហាក់បាន ឆ្នាំ ២៥៥ សករាជ ហ៊ីជ្ជរ៉ោះត៏ នៅសាម៉ាររ៉អ៊ុ |

# លំហាត់ ៤-៥

១-ចូរប្រាប់ថ្ងៃកំណើតរបស់អ៊ីម៉ាំទី ២ របស់យើងصلوات الله عليه والسلام ។
២-តើអ៊ីម៉ាំ អាុលី អាន់-ណាគ្គីصلوات الله عليه والسلامប្រសូតនៅស្រុកណា ?
៣-តើអ៊ីម៉ាំទី ៧ របស់យើងصلوات الله عليه والسلامមានព្រះនាមអ្វី ?
៤-តើអ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាល់-បាគៀរصلوات الله عليه والسلامប្រសូតថ្ងៃណា ?
៥-តើអ៊ីម៉ាំទី ១ របស់យើងصلوات الله عليه والسلامប្រសូតនៅស្រុកណា ?

# មេរៀនទី ៦-៧

## ថ្ងៃនិងកន្លែងពលីកម្មរបស់អាអ៊ីម៉ាស់ عليهم السلام

ថ្ងៃពលីកម្ម (ស្លាប់ដោយឃាតកម្ម) របស់អ៊ីម៉ាំនីមួយ صلوات الله عليه والسلام របស់យើងជាឱកាសសោកសៅបំផុតមួយសម្រាប់យើង ។ ជាថ្ងៃដែលយើងបានបាត់បង់ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام យើង ។

ដូច្នេះរៀងរាល់ឆ្នាំ ក្នុងថ្ងៃដែលអ៊ីម៉ាំនីមួយៗ صلوات الله عليه والسلام សោយទិវង្គត យើងស្លៀកពាក់ខ្មៅ យើងទៅម៉ាស់យ៉ិដ្ឋ ស្តាប់ឃុត្ហ្បាស់ ដើម្បីស្គាល់អ៊ីម៉ាំដែលសោយទិវង្គនោះនិងអ្វីដែលព្រះអង្គបានបង្ហាត់បង្រៀនយើង ដើម្បីយើងនឹងអាចកែខ្លួនឲ្យកាន់តែប្រសើរឡើងបាន ។

បើយើងបណ្តោយឲ្យថ្ងៃនេះកន្លងផុតទៅ ដោយពុំបានសិក្សានិងកែខ្លួនឲ្យកាន់តែល្អឡើងទេនោះ ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام យើងបានសោយទិវង្គតដោយឥតប្រយោជន៍ ។

| អ៊ីម៉ាំ | ថ្ងៃនិងកន្លែងពលីកម្ម |
|---|---|
| ១-អ៊ីម៉ាំ អាលី صلوات الله عليه والسلام | ២១ រ៉ម៉ាដូន ឆ្នាំ ៤០ សករាជហ៊្ជីរ៉ោះត៍ នៅគូហ្វាស់ |
| ២-អ៊ីម៉ាំ ហាសាន់ صلوات الله عليه والسلام | ៧ ស៍ហ្វារ ឆ្នាំ ៥០ សករាជហ៊្ជីរ៉ោះត៍ នៅម៉ាឌីណាស់ |
| ៣-អ៊ីម៉ាំ ហ៊ូសែន៍ صلوات الله عليه والسلام | ១០ មូហារ៉ម ឆ្នាំ ៦១ សករាជហ៊្ជីរ៉ោះត៍ នៅការបាឡាអ៍ |
| ៤-អ៊ីម៉ាំ អាលី ស៊ែនុល អាប៊ីឌីន صلوات الله عليه والسلام | ២៥ មូហារ៉ម ឆ្នាំ ៩៥ សករាជហ៊្ជីរ៉ោះត៍ នៅម៉ាឌីណាស់ |
| ៥-អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام | ៧ ស៊ុលហ៊ីជ្ជយ៉ាស់ ឆ្នាំ ១១៤ សករាជហ៊្ជីរ៉ោះត៍ នៅម៉ាឌីណាស់ |
| ៦-អ៊ីម៉ាំ យ៉ាក់ហ្វារ អាស់-ស៍ឌិក្ល صلوات الله عليه والسلام | ២៥ ស្ងៅវ៉ាល់ ឆ្នាំ ១៤៨ សករាជហ៊្ជីរ៉ោះត៍ នៅម៉ាឌីណាស់ |

| | |
|---|---|
| ៧-អ៊ីម៉ាំ មូសា អាល់-កាស្ហ៊ីម صلوات الله عليه والسلام | ២៥ រ៉យ៉ាប់ ឆ្នាំ ១៨៣ សករាជហ្ញិច្ចរ៉ោះត៍ នៅបាក់ដ្ហាដ់ |
| ៨-អ៊ីម៉ាំ អ្ហលី អារ-រីដ្ហ៍ صلوات الله عليه والسلام | ២៩ ស្វ៍ហ្វារ ឆ្នាំ ២០៣ សករាជហ្ញិច្ចរ៉ោះត៍ នៅម៉ាស្ហ៍ហ្វាដ់ |
| ៩-អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាត់-តាគ្គី صلوات الله عليه والسلام | ២៩ ស្ហ៊ុលកក្កុំដ្ហាស់ ឆ្នាំ ២២០ សករាជ ហ្ញិច្ចរ៉ោះត៍ នៅកាស្ហ៊ីម៉ែន៍ |
| ១០-អ៊ីម៉ាំ អ្ហលី អាន់-ណាគ្គី صلوات الله عليه والسلام | ៣ រ៉យ៉ាប់ ឆ្នាំ ២៥៤ សករាជហ្ញិច្ចរ៉ោះត៍ នៅសាម៉ាររ៉អ៍ |
| ១១-អ៊ីម៉ាំ ហ្ហាសាន់ អាល់-អ្ហស់ការី صلوات الله عليه والسلام | ៨ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំ ២៦០ សករាជ ហ្ញិច្ចរ៉ោះត៍ នៅសាម៉ាររ៉អ៍ |
| ១២-អ៊ីម៉ាំ មូហ៊ាំម៉ាដ់ អាល់-ម៉ាស្ហ៍ឌី صلوات الله عليه والسلام | ព្រះអង្គ صلوات الله عليه والسلام គង់ព្រះជន្មនៅឡើយ |

## លំហាត់ ៦-៧

ចូរគូសឈ្មោះអ៊ីម៉ាំនីមួយៗភ្ជាប់នឹងថ្ងៃពលីកម្មរបស់ព្រះអង្គ صلوات الله عليه والسلام ។

១-អ៊ីម៉ាំ អាលី صلوات الله عليه والسلام
២-អ៊ីម៉ាំ ហាសាន់ صلوات الله عليه والسلام
៣-អ៊ីម៉ាំ ហ៊ូសែន៍ صلوات الله عليه والسلام
៤-អ៊ីម៉ាំ អាលី សៃនុល អាប៊ីឌីន صلوات الله عليه والسلام
៥-អ៊ីម៉ាំ មូហាំម៉ាដ់ អាល់-បាកៀរ صلوات الله عليه والسلام
៦-អ៊ីម៉ាំ យ៉ាក់ហ្វារ អាស់-ស៍ឌិក្ក صلوات الله عليه والسلام
៧-អ៊ីម៉ាំ មូសា អាល់-កាស៊ីម صلوات الله عليه والسلام
៨-អ៊ីម៉ាំ អាលី អារ-រីដ៏ صلوات الله عليه والسلام
៩-អ៊ីម៉ាំ មូហាំម៉ាដ់ អាត់-តាគី صلوات الله عليه والسلام
១០-អ៊ីម៉ាំ អាលី អាន់-ណាគី صلوات الله عليه والسلام
១១-អ៊ីម៉ាំ ហាសាន់ អាល់-អាស់ការី صلوات الله عليه والسلام

ក) ២៩ ស៊ុលក្កក់ដាស់
ខ) ៨ រ៉ប៊ីអ៊ុល អាវ៉ាល់
គ) ២១ រ៉ម៉ាដូន
ឃ) ៣ រ៉យ៉ាប់
ង) ៧ ស៍ហ្វារ
ច) ១០ មូហាររ៉ម
ឆ) ២៥ មូហាររ៉ម
ជ) ៧ ស៊ុលហ៊ីច្ចយ៉ាស់
ឈ) ២៥ រ៉យ៉ាប់
ញ) ២៩ ស៍ហ្វារ
ដ) ២៥ ស្សៅវ៉ាល់

# មេរៀនទី ៨-៩

## ឋានន្តររបស់អាអ៊ីម៉ាស់ عليهم السلام

ឋានន្តរគឺឈ្មោះចំតើតឬងាររបស់អាអ៊ីម៉ាស់ ។

អ៊ីមុាំទាំងអស់ عليهم السلام របស់យើងសុទ្ធតែមានព្រះនាមចំតើតមួយ ដែលគេដាក់ឲ្យព្រោះព្រះអង្គ عليهم السلام ប្រកបដោយព្រះគុណសម្បត្តិពិសេសនៅក្នុងខ្លួន ។

ឋានន្តរសាមញ្ញជាងគេរបស់អ៊ីមុាំនីមួយ صلوات الله عليه والسلام គឺ៖

| អ៊ីមុាំ | ឋានន្តរ | អត្ថន័យ |
|---|---|---|
| ១ | អាមីរុល-មុមីនីន صلوات الله عليه والسلام (أمير المؤمنين) | ព្រះអគ្គប្រមុខរបស់អ្នកមានសទ្ធា |
| ២ | អាល់-មុច្ចតាបា صلوات الله عليه والسلام (المجتبى) | បុគ្គលត្រូវជ្រើសរើស |
| ៣ | សៃយីឌុស្ស-ស៊ូហាដាអ៊ុ صلوات الله عليه والسلام (سيد الشهداء) | ម្ចាស់របស់អស់ទុក្ករបុគ្គល |
| ៤ | ស្សៃនុល អាុប៊ីឌីន صلوات الله عليه والسلام (زين العابدين) | អ្នកស្មោះស្ម័គ្រប្រសើរដាច់គេ |
| ៥ | អាល់-បាក្វៀរ صلوات الله عليه والسلام (الباقر) | អ្នកឲ្យចំណេះ |
| ៦ | អាស្ស៊-ស្ស៊ឌិក្វ صلوات الله عليه والسلام (الصادق) | សច្ចការី |
| ៧ | អាល់-កាស្ស៊ិម صلوات الله عليه والسلام (الكاظم) | បុគ្គលប្រកបដោយអំណត់ |
| ៨ | អារ-រីឌ្ហ៊ំ صلوات الله عليه والسلام (الرضا) | បុគ្គលស្កប់ចិត្ត |
| ៩ | អាត់-តាគ្គី صلوات الله عليه والسلام (التقي) | បុគ្គលជឿស៊ប់ចិត្ត |
| ១០ | អាន់-ណាគ្គី صلوات الله عليه والسلام (النقي) | បុគ្គលបរិសុទ្ធ |
| ១១ | អាល់-អាុស់ការី صلوات الله عليه والسلام (العسكري) | អ្នកជិតខាងរបស់យោធា |
| ១២ | អាល់-ម៉ាស្ស៊ហ្ឌី صلوات الله عليه والسلام (المهدي) | បុគ្គលដែលគេណែនាំ |

## លំហាត់ ៨-៩

ចូររៀបពាក្យទាំងនេះឲ្យត្រឹមត្រូវ ដើម្បីផ្គុំបាននូវស័ក្តិរបស់អ៊ីម៉ាំ عليهم السلام យើងឡើងវិញគឺ៖ ព្រះអគ្គប្រមុខរបស់យោធា, អ្នកចេះដឹងប្រសើរដាច់គេ, បុគ្គលស្អប់ចិត្តក្នុងចំណោមទុក្ករបុគ្គល, អ្នកជិតខាងរបស់បុគ្គលដែលត្រូវជ្រើសរើស, បុគ្គលបរិសុទ្ធរបស់បុគ្គលដែលគេណែនាំ, សច្ចការីរបស់បុគ្គលដែលជឿស៊ប់ចិត្ត, អ្នកឲ្យរបស់បុគ្គលដែលប្រកបដោយអំណាត់ ។

| | |
|---|---|
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

# មេរៀនទី ១០

## រៀនសាឡើងវិញទាំងអស់អំពីអាអ៊ីម៉ាស់ عليهم السلام

| ឋានន្តរ | បិតា | មាតា | ថ្ងៃបុណ្យខួបកំណើត | ថ្ងៃចូលទិវង្គត |
|---|---|---|---|---|
| ១.អាមីរុល-មុមីនីន صلوات الله عليه والسلام | អាប៊ូ ត៉ូលិប | ហ្វាទីម៉ាស់ ប៊ិនទី អាសាដ់ سلام الله عليها | ១៣ រ៉យ៉ាប់ ២៣ ឆ្នាំមុន ស. ហ. ម៉ាក់កាស់ | ២១ រ៉ម៉ាដន ឆ្នាំ ៤០ ស. ហ. គូហ្វាស់ |
| ២.អាល់-មុច្តាបា صلوات الله عليه والسلام | អ៊ីម៉ាំទី ១ | ហ្វាទីម៉ាស់ អាស់សាស់រ៉អ៊ سلام الله عليها | ១៥ រ៉ម៉ាដន ឆ្នាំ ៣ ស. ហ. ម៉ាឌីណាស់ | ៧ ស្វហ្វារ ឆ្នាំ ៥០ ស. ហ. ម៉ាឌីណាស់ |
| ៣.សៃយីឌុស្ស-ស្សហ្វាដាអ៊ صلوات الله عليه والسلام | អ៊ីម៉ាំទី ១ | ហ្វាទីម៉ាស់ អាស់សាស់រ៉អ៊ سلام الله عليها | ៣ ស្សាក់បាន ឆ្នាំ ៤ ស.ហ. ម៉ាឌីណាស់ | ១០ មូហារ៉ម ឆ្នាំ ៦១ ស. ហ. ការបាឡាអ៊ |
| ៤.សៃនុល-អាប៊ីឌីន صلوات الله عليه والسلام | អ៊ីម៉ាំទី ៣ | ស្សាស់រ៉បានូ | ៥ ស្សាក់បាន ឆ្នាំ ៣៨ ស.ហ. ម៉ាឌីណាស់ | ២៥ មូហារ៉ម ឆ្នាំ ៩៥ ស. ហ. ម៉ាឌីណាស់ |
| ៥.អាល់-បាក៊ៀរ صلوات الله عليه والسلام | អ៊ីម៉ាំទី ៤ | ហ្វាទីម៉ាស់ ប៊ិនទី អាល់-ហាសាន់ | ១ រ៉យ៉ាប់ ឆ្នាំ ៥៧ ស.ហ. ម៉ាឌីណាស់ | ៧ ស៊ុលហ៊ីច្ចយ៉ាស់ ឆ្នាំ ១១៤ ស. ហ. ម៉ាឌីណាស់ |
| ៦.អាស្វ-ស្វឌិក្ក صلوات الله عليه والسلام | អ៊ីម៉ាំទី ៥ | ហ្វាទីម៉ាស់ (អ៊ូម ហ្វារវ៉ាស់) | ១៧ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំ ៨៣ ស.ហ. ម៉ាឌីណាស់ | ២៥ ស្សៅវ៉ាល់ ឆ្នាំ ១៤៨ ស. ហ. ម៉ាឌីណាស់ |
| ៧.អាល់-កាស៊ីម صلوات الله عليه والسلام | អ៊ីម៉ាំទី ៦ | ហាមីដាស់ | ៧ ស្វហ្វារ ឆ្នាំ ១២៨ ស.ហ. | ២៥ រ៉យ៉ាប់ ឆ្នាំ ១៨៣ ស. ហ. |

| | | | | |
|---|---|---|---|---|
| | | | អាប់វ៉ាអ៊ុ | បាក្ខុំដ្វាដ្ជុំ |
| ៨.អារ-រីជ្ជុំ صلوات الله عليه والسلام | អ៊ីមុាំទី ៧ | អ៊្វមុល-បានីន ណាច្ចុំម៉ាស្ទុំ | ១១ ស្ទុំលក្ខក្ខុំដ្វាស្ទុំ ឆ្នាំ ១៤៨ ស.ហ. ម៉ាឌីណាស្ទុំ | ២៩ ស្ទុំហ្វារ ឆ្នាំ ២០៣ ស. ហ. ម៉ាស្ទុំហ្វាដ្ជុំ |
| ៩.អាត់-តាគ្គី صلوات الله عليه والسلام | អ៊ីមុាំទី ៨ | សាប៊ីកាស្ទុំ ខុយស្ទុរ៉ាន | ១០ រ៉យ៉ាប់ ឆ្នាំ ១៩៥ ស.ហ. ម៉ាឌីណាស្ទុំ | ២៩ ស្ទុំលក្ខក្ខុំដ្វាស្ទុំ ឆ្នាំ ២២០ ស. ហ. កាស្ទុំម៉ៃន៍ |
| ១០.អាន់-ណាគ្គី صلوات الله عليه والسلام | អ៊ីមុាំទី ៩ | ស្ទូម៉ាណា | ១៥ ស្ទុំលហ៊ីច្ចុយ៉ាស្ទុំ ឆ្នាំ ២១២ ស.ហ. ស្ទូរបាស្ទុំ | ៣ រ៉យ៉ាប់ ឆ្នាំ ២៥៤ ស. ហ. សាម៉ាររ៉អ៊ុំ |
| ១១.អាល់-អាស្ទុំការី صلوات الله عليه والسلام | អ៊ីមុាំទី ១០ | ស្ទូឡៃល៍ ឬ សៅសាន | ១០ រ៉ប៊ីអ៊ុល អាខ្ចៀរ ឆ្នាំ ២៣២ ស.ហ. ម៉ាឌីណាស្ទុំ | ៨ រ៉ប៊ីអ៊ុល អាវ៉ាល់ ឆ្នាំ ២៦០ ស. ហ. សាម៉ាររ៉អ៊ុំ |
| ១២.អាល់-ម៉ាស្ទុំឌី صلوات الله عليه والسلام | អ៊ីមុាំទី ១១ | ណារយ៉ូស | ១៥ ស្ទាក្ខុំបាន ឆ្នាំ ២៥៥ ស.ហ. សាម៉ាររ៉អ៊ុំ | ព្រះអង្គ صلوات الله عليه والسلام គង់ព្រះជន្មនៅឡើយ |

# មេរៀនទី ១១

## សៃយីដ្ហាស្ហ់ខ្ហ៏ឌ្ហីយ៉្ជាស្ហ់ سلام الله عليها

សៃយីដ្ហាស្ហ់ ខ្ហ៏ឌ្ហីយ៉្ជាស្ហ់ سلام الله عليها ជាព្រះមហេសីដំបូងរបស់ព្រះសាស្តា صلى الله عليه وآله وسلم ជាព្រះមាតារបស់សៃយីដ្ហាស្ហ់ ហ្វាទីម៉ាស្ហ់ سلام الله عليها ។ ព្រះនាង سلام الله عليها ប្រសូតនៅឯម៉ាក់កាស្ហ់ ។ បិតាព្រះនាង سلام الله عليها ឈ្មោះ ឃ្ជូវៃលីដ្ហ ប៊ិន អាសាដ្ហ់ (خويلد بن أسد) ជាឈ្មួញស្តុកស្តម្ភម្នាក់ ។

ពេលបិតាព្រះនាង سلام الله عليها ស្លាប់ សៃយីដ្ហាស្ហ់ ខ្ហ៏ឌ្ហីយ៉្ជាស្ហ់ទទួលកិច្ចការជួសបិតាបន្តការចាត់បញ្ជូនក្រុមជួញដូរចល័តទៅប្រទេសស៊ីរីនិងប្រទេសយេមែន ។ ព្រះនាង سلام الله عليها បានក្លាយទៅជាស្ត្រីឈ្មួញមានជាងទេនៅម៉ាក់កាស្ហ់យ៉ាងឆាប់ គេហៅព្រះនាង سلام الله عليها ថា "អង្គម្ចាស់ក្សត្រីនៃនគរម៉ាក់កាស្ហ់" ។

ព្រះសាស្តា صلى الله عليه وآله وسلم ប្រកបកិច្ចការឲ្យសៃយីដ្ហាស្ហ់ខ្ហ៏ឌ្ហីយ៉្ជាស្ហ់ سلام الله عليها ។ សៃយីដ្ហាស្ហ់ខ្ហ៏ឌ្ហីយ៉្ជាស្ហ់ سلام الله عليها ស្នើចព្រះសាស្តា صلى الله عليه وآله وسلم បន្ទាប់មកព្រះអង្គ صلى الله عليه وآله وسلم និងសៃយីដ្ហាស្ហ់ខ្ហ៏ឌ្ហីយ៉្ជាស្ហ់ سلام الله عليها ក៏បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ។ កាលរៀបអាពាហ៍ពិពាហ៍នោះ ព្រះសាស្តា صلى الله عليه وآله وسلم មានព្រះជន្ម ២៥ ឆ្នាំ ចំណែកឯសៃយីដ្ហាស្ហ់ខ្ហ៏ឌ្ហីយ៉្ជាស្ហ់ سلام الله عليها មានអាយុ ៤០ ឆ្នាំ ។ ព្រះសាស្តា صلى الله عليه وآله وسلم និងសៃយីដ្ហាស្ហ់ខ្ហ៏ឌ្ហីយ៉្ជាស្ហ់ سلام الله عليها មានកូនប្រុសពីរនាក់ ។ កូនប្រុសដំបូងឈ្មោះ ក៏្ហស៊ីម (القاسِم) កូនប្រុសទីពីរឈ្មោះ អ៊្ហប់ឌុ្ហលឡោះហ្ញ៍ ។ កូនប្រុសទាំងពីរបានស្លាប់កាលពីនៅក្មេងនៅឡើយ ព្រះសាស្តា صلى الله عليه وآله وسلم សៅហ្មងណាស់ ។ ពេលអ៊ីមុាំអ៊្ហលី صلوات الله عليه والسلام ប្រសូត ព្រះអង្គ صلى الله عليه وآله وسلم បានយកព្រះអង្គ صلوات الله عليه والسلام មកចិញ្ចឹមឯផ្ទះព្រះអង្គ صلى الله عليه وآله وسلم ដូចកូនបង្កើត ។

បន្ទាប់មក ព្រះសាស្តា صلى الله عليه وآله وسلم និងសៃយីដ្ហាស្ហ់ខ្ហ៏ឌ្ហីយ៉្ជាស្ហ់ سلام الله عليها បានបុត្រីមួយ ព្រះសាស្តា صلى الله عليه وآله وسلم ដាក់ឈ្មោះឲ្យថា ហ្វាទីម៉ាស្ហ់ អាស្ញ់-ស្ញាស្ហ់រ៉អ៊្ហ سلام الله عليها ។

ព្រះសាស្តា صلى الله عليه وآله وسلم ធ្លាប់តែលះបង់ពេលវេលាច្រើន នៅក្នុងរូងភ្នំហ៊្ជីរ៉អ៊្ហក្បែរម៉ាក់កាស្ហ់ ។ ព្រះអង្គ صلى الله عليه وآله وسلم គិតដល់អល់ឡោះហ្ញ៍ عز وجل និងគិតអំពីអ្វីៗដែលព្រះអង្គ صلى الله عليه وآله وسلم បានបង្កើតមក ។ ជួនកាលព្រះអង្គ صلى الله عليه وآله وسلم នៅក្នុងរូងភ្នំនោះច្រើនថ្ងៃ ហើយក៏ត្រឡប់ទៅលំនៅដ្ឋានវិញ ។

សៃយីដ្ទាស្ហ់ខ៊ិ៍ឌ្ទីយ៉ាស្ហ់سلام الله عليهاទៅលេងព្រះអង្គصلى الله عليه وآله وسلمដោយស្ម័គ្រស្មោះ យកអាហារមកឲ្យព្រះអង្គصلى الله عليه وآله وسلم មិនឲ្យព្រះអង្គصلى الله عليه وآله وسلمខ្វះខាតទេ ។

ពេលអល់ឡោះហ្វ៏عز وجلដាក់ព្រះបញ្ជា ឲ្យព្រះសាស្ដាصلى الله عليه وآله وسلمផ្សាយសាសនាអ៊ីស្លាម សៃយីដ្ទាស្ហ់ខ៊ិ៍ឌ្ទីយ៉ាស្ហ់سلام الله عليهاជាស្ត្រីដំបូងបង្អស់ដែលព្រមទទួលព្រះធម៌ ហើយទៅជានារីមុស្លីម ។ ព្រះនាងسلام الله عليهاបានលះបង់ទ្រព្យសម្បត្តិទាំងអស់ដើម្បីជ្រោមជ្រែងសាសនាអ៊ីស្លាម ។

សៃយីដ្ទាស្ហ់ខ៊ិ៍ឌ្ទីយ៉ាស្ហ់سلام الله عليهاបានរួមរស់ជាមួយព្រះសាស្ដាصلى الله عليه وآله وسلم ជាស្វាមីភរិយាអស់រយៈពេល ២៥ ឆ្នាំ ។ ព្រះនាងសោយទិវង្គតថ្ងៃទី ១០ ខែ រ៉ម៉ាដ្ទន ៣ ឆ្នាំមុនសករាជហ៊្ស៊ីច្រ៉េាះត៏ ។ សពព្រះនាងسلام الله عليهاបញ្ចុះនៅឯម៉ាក់កាស្ហ់ ។

ក្នុងឆ្នាំតែមួយនេះ ព្រះសាស្ដាصلى الله عليه وآله وسلمបានបាត់បង់ អាប៊ូ ត៉្លិប ឪពុកមាព្រះអង្គصلى الله عليه وآله وسلم ។ ព្រឹត្តិការណ៍ទាំងពីរនេះធ្វើឲ្យព្រះអង្គصلى الله عليه وآله وسلمសោកសៅហ្មងជាទីបំផុត ព្រះអង្គصلى الله عليه وآله وسلمហៅឆ្នាំនេះថា "អ៊ាមុល-ហ៊ុស្និ (عَامَ الْحُزْنِ)" មានន័យឆ្នាំសោកសង្រេង ។

កាលសៃយីដ្ទាស្ហ់ខ៊ិ៍ឌ្ទីយ៉ាស្ហ់سلام الله عليهاនៅរស់ ព្រះសាស្ដាصلى الله عليه وآله وسلمមិនរៀបការជាមួយស្ត្រីឯទៀតទេ ច្រើនឆ្នាំក្រោយមកព្រះអង្គصلى الله عليه وآله وسلمបានថាព្រះនាងسلام الله عليهاជាភរិយាដែលប្រសើរលើសអស់ភរិយា ។ ព្រះអង្គصلى الله عليه وآله وسلمមានព្រះវចនៈដែរថាព្រះនាងسلام الله عليهاជាស្ត្រីសុក្រឹតឥតខ្ចោះក្នុងចំណោមស្ត្រីសុក្រឹតឥតខ្ចោះទាំងបួននៅលើផែនដី ។ ស្ត្រីសុក្រឹតឥតខ្ចោះបីនាក់ទៀតគឺ សៃយីដ្ទាស្ហ់អាស៊ីយ៉ាស្ហ់سلام الله عليها មហេសីរបស់ហ្វៀរអ៊ុន៍لعنه الله, សៃយីដ្ទាស្ហ់ម៉ារយុំ ព្រះមាតារបស់ព្រះសាស្ដាអ៊ីសាعليه السلام, សៃយីដ្ទាស្ហ់ហ្វាទីម៉ាស្ហ់ អាស្ហ៍-ស្ហាស្ហ់រ៉អ៊ុ័سلام الله عليها ។

# លំហាត់ ១១

ចូរជ្រើសយកចម្លើយត្រឹមត្រូវ ។

១. សៃយីដ្ហាស្ជ់ខ៊្ឌីយ៉ាស្ជ់ជាមហេសីទី.....របស់ព្រះសាស្តាﷺ ។

ក) ១

ខ) ២

គ) ៣

ឃ) ៤

២. សៃយីដ្ហាស្ជ់ខ៊្ឌីយ៉ាស្ជ់ប្រសូតនៅឯ........ ។

ក) ម៉ាក់កាស្ជ់

ខ) ម៉ាឌីណាស្ជ់

គ) ប្រទេសស៊ីរី

ឃ) ប្រទេសយេមែន

៣. បិតារបស់សៃយីដ្ហាស្ជ់ខ៊្ឌីយ៉ាស្ជ់មានមុខរបរជា........ ។

ក) កសិករ

ខ) ពេទ្យ

គ) គ្រូបង្រៀន

ឃ) ឈ្មួញ

៤) បិតារបស់សៃយីដ្ហាស្ជ់ខ៊្ឌីយ៉ាស្ជ់ឈ្មោះ....... ។

ក) ឃ៉ូវៃលីដ្ឋ ប៊ិន មូហ្គាំម៉ាដ្ជ់

ខ) កាស៊ីម ប៊ិន អាសាដ្ជ់

គ) មូសា អាល់-កាស្ទ៊ីម

ឃ) ឃ៉ូវៃលីដ្ឋ ប៊ិន អាសាដ្ជ់

៥) គេហៅសែយីដ្ហាស់ខ៊ុំឌីយ៉ាស់ថា...... ។
ក) ក្សត្រីនៃស្រុកម៉ាក់កាស់
ខ) អង្គម្ចាស់ក្សត្រីនៃនគរម៉ាក់កាស់
គ) អង្គម្ចាស់ក្សត្រីនៃស្រុកម៉ាឌីណាស់
ឃ) អង្គម្ចាស់ក្សត្រីនៃប្រទេសយេមេន

៦) កាលរៀបអាពាហ៍ពិពាហ៍ជាមួយរ៉ស៊ូលុលឡោះហ៍ﷺ សែយីដ្ហាស់ខ៊ុំឌីយ៉ាស់មានអាយុ...... ។
ក) ២០ ឆ្នាំ
ខ) ២៥ ឆ្នាំ
គ) ៤៥ ឆ្នាំ
ឃ) ៤០ ឆ្នាំ

៧) កូនប្រុសទាំងពីររបស់រ៉ស៊ូលុលឡោះហ៍ﷺ និងសែយីដ្ហាស់ខ៊ុំឌីយ៉ាស់ឈ្មោះ.......... ។
ក) ក៏ស៊ីមនិងអ៊ាប់ឌុលឡោះហ៍
ខ) ក៏ស៊ីមនិងអ៊ាប់បាស់
គ) ឃ្វ៉លីដ្ធនិងអ៊ាប់ឌុលឡោះហ៍
ឃ) មូហ៊ាំម៉ាដ្ធនិងក៏ស៊ីម

៨) កូនទាំងពីររបស់រ៉ស៊ូលុលឡោះហ៍ﷺនិងសែយីដ្ហាស់ខ៊ុំឌីយ៉ាស់..... ។
ក) បានយកមុខរបរជួញដូររបស់គ្រួសារ
ខ) បានរៀនសូត្រជ្រាលជ្រៅ
គ) បានបាត់ខ្លួន
ឃ) បានស្លាប់កាលពីនៅក្មេងនៅឡើយ

៩) កូនស្រីរបស់រ៉ស៊ូលុលឡោះហ៍ﷺនិងសែយីដ្ហាស់ខ៊ុំឌីយ៉ាស់ឈ្មោះ.... ។

ក) ហ្វាទីម៉ាស្ហ៍ អាស្ង់-ស្ងាស្ង់រ៉

ខ) អ៊ុម គុលស៊ូម

គ) ស្ងៃណាប់

ឃ) សាគីណាស្ហ៍

១០) រ៉ស៊ូលុលឡោះហ្ ﷺ លះបង់ពេលវេលាច្រើននៅឯ.... ។

ក) រូងភ្នំប្រទេសយេមេន

ខ) រូងភ្នំហ៊ីរ៉អ៍

គ) កាក្ហ៍បាស្ហ៍

ឃ) ក្នុងវាលរហោឋាន

១១) សៃយីដាស្ហ៍ខ៍ឌីយ៉ាស្ហ៍បានលះបង់ប្រាក់ទាំងអស់ដើម្បី..... ។

ក) ធ្វើបុណ្យរៀបការព្រះនាង سلام الله عليها

ខ) ទិញហាងលក់ដូរពីគេ

គ) បង់ថ្លៃសាលារបស់កូនៗព្រះនាង سلام الله عليها

ឃ) ជ្រោមជ្រែងសាសនាអ៊ីស្លាម

១២) សៃយីដាស្ហ៍ខ៍ឌីយ៉ាស្ហ៍សោយទិវង្គតថ្ងៃ..... ។

ក) ទី ៨ ខែរ៉ម៉ាឌ្ហន

ខ) ទី ១០ ខែរ៉ម៉ាឌ្ហន

គ) ទី ១២ ខែរ៉ម៉ាឌ្ហន

ឃ) ១០ មូហារ៉ម

១៣) ក្នុងឆ្នាំតែមួយ រ៉ស៊ូលុលឡោះហ្ ﷺ បានបាត់បង់.......ដែរ ។

ក) អាប់ឌុលឡោះហ្ កូនប្រុសព្រះអង្គ ﷺ

ខ) ក្ហ៍ស៊ីម កូនប្រុសព្រះអង្គ ﷺ

គ) អាប៊ូ ត្ហ៍លិប ឪពុកមាព្រះអង្គ ﷺ

ឃ) យ៉ូវ៉ៃលីដូ ឪពុកមាព្រះអង្គﷺ

១៤) អ៊ាមុល-ហ៊ុសនីមានន័យថា..... ។
ក)ឆ្នាំរីករាយ
ខ) ឆ្នាំអពមង្គល
គ) ឆ្នាំកំណើត
ឃ) ឆ្នាំសោកសង្រេង

១៥) សៃយីដ្ធាស់អាសុីយ៉ាស់سلام الله عليها ស្រ្តីសុក្រឹតម្នាក់ក្នុងចំស្រ្តីសុក្រឹតទាំង ៤ ជា..... ។
ក) មហេសីរបស់ហ្វៀរអ៊ាន់لعنه الله
ខ) មហេសីទីមួយរបស់រ៉ស៊ូលុលឡោះហ៍ﷺ
គ) ព្រះមាតារបស់ព្រះសាស្តាអ៊ីសាعليه السلام
ឃ) ព្រះមាតារបស់អ៊ីម៉ាំអ៊ាលីصلوات الله عليه والسلام

# មេរៀនទី ១២

## សៃយីដាស់ ហ្វាទីម៉ាស់ អាស់-សាស់រ៉អ៊៍سلام الله عليها

សៃយីដាស់ ហ្វាទីម៉ាស់ អាស់-សាស់រ៉អ៊៍سلام الله عليها ស្ត្រីប្រសើរជាច់អស់ស្ត្រី ជាព្រះរាជបុត្រីមួយគត់របស់ព្រះសាស្តាﷺនិងសៃយីដាស់ខ៊ទីយ៉ាស់سلام الله عليها ។

ព្រះនាងسلام الله عليهاប្រសូតនៅឯម៉ាក់កាស់ថ្ងៃទី ២០ ខែ យុម៉ាដា អាល់-អាឃ៊ីរ៉ោះត៍ (جُمَادَى الآخِرَة) ៨ ឆ្នាំមុនសករាជហ៊ីជ្រ៉ោះត៍ ក្រោយអល់ឡោះហ្ជ៍ﷻបានដាក់ ស៊ូរ៉ោះត៍ អាល់-កៅស្ឍ៊រមកឲ្យព្រះសាស្តាﷺ ។

សត្រូវមួយចំនួនរបស់ព្រះសាស្តាﷺបានប្រមាថព្រះអង្គﷺ ។ សត្រូវខ្លះហៅព្រះអង្គﷺថា "អាប់តារ" មានន័យថាសត្វដាច់កន្ទុយ ។ ពួកសត្រូវទាំងនោះចង់ថាព្រះសាស្តាﷺពុំមានកូនស្នងព្រះអង្គﷺទេ ដើម្បីលើកស្ទួយឈ្មោះព្រះអង្គﷺចំណេរកាលតទៅ បណ្តាលឲ្យព្រះសាស្តាﷺសោកសៅអនេករហូតដល់អល់ឡោះហ្ជ៍ﷻបានដាក់ស៊ូរ៉ោះត៍ អាល់-កៅស្ឍ៊រចុះមកជាចម្លើយតបមនុស្សកំណាចទាំងនោះ ។

إِنَّآ أَعۡطَيۡنَٰكَ ٱلۡكَوۡثَرَ ١ فَصَلِّ لِرَبِّكَ وَٱنۡحَرۡ ٢ إِنَّ شَانِئَكَ هُوَ ٱلۡأَبۡتَرُ ٣

*១. ពិតណាស់ យើងបានប្រទានអាល់-កៅស្ឍ៊រឲ្យអ្នក ។ ២. ដូច្នេះចូរអ្នកធ្វើនមស្ការបូជាព្រះម្ចាស់អ្នកនិងធ្វើពលិកម្ម ។ ៣. ពិតណាស់ សត្រូវរបស់អ្នកជាមនុស្សដាច់ពូជ ។*(១០៨:១-៣)

អាយ៉ាស់នេះសន្យាព្រះសាស្តាﷺថាព្រះអង្គﷺនឹងពុំឥតកូនទេ ក្រោយមកបន្តិចព្រះរាជបុត្រីមួយអង្គបានប្រសូតមក ។ ព្រះសាស្តាﷺដាក់ព្រះនាមឲ្យព្រះរាជបុត្រីថា ហ្វាទីម៉ាស់ អាស់-សាស់រ៉អ៊៍سلام الله عليها ។ សៃយីដាស់ហ្វាទីម៉ាស់سلام الله عليهاក៏បានទៅជាព្រះមាតារបស់ព្រះសន្តអាអ៊ីម៉ាស់عليهم السلامយើង តាមរយៈចៅៗរបស់ព្រះសាស្តាﷺព្រះនាមរបស់ព្រះអង្គﷺគង់នៅជាអនន្ត ។ សព្វថ្ងៃនេះបណ្តាកូនចៅរបស់ព្រះសាស្តាﷺមានវត្តមាននៅគ្រប់ទីកន្លែងក្នុងលោក គេហៅបណ្តាកូនចៅរបស់ព្រះអង្គﷺ

ទាំងនោះថា *សៃយីដ្* ។ តែគេពុំឃើញមានអ្នកណាមួយថាខ្លួនជាកូនចៅរបស់ពួកសត្រូវរបស់ព្រះសាស្តាﷺទេ ។ នេះគឺសន្យារបស់អល់ឡោះហ៍عز وجلនៅក្នុងស៊ូរ៉ោះត៍ខាងលើនេះ ពេលព្រះអង្គعز وجلមានព្រះបន្ទូលថា៖ "ពិតណាស់ ពួកសត្រូវរបស់អ្នកជាមនុស្ស "អាប់តារ" (គឺដាច់ពូជ)" ។

ព្រះនាងហ្វាទីម៉ាស់سلام الله عليهاសោយទិវង្គតនៅម៉ាឌីណាស់ ថ្ងៃទី ៣ ខែ យូម៉ាដា អាល់-អាឃិរ៉ោះត៍ ៧៥ ថ្ងៃក្រោយព្រះបិតាព្រះនាងسلام الله عليها គឺក្រោយព្រះសាស្តាﷺ សោយទិវង្គត ៧៥ ថ្ងៃ ។

រាល់ពេលដែលសៃយីដាស់ហ្វាទីម៉ាស់سلام الله عليهاមកជួបព្រះសាស្តាﷺ ព្រះសាស្តាក្រោកឈរដោយគោរព ពុំមែនព្រោះតែព្រះនាងسلام الله عليهاជាកូនព្រះអង្គﷺទេ តែព្រោះតែព្រះនាងسلام الله عليهاជាស្ត្រីដែលមានជំនឿស៊ប់ចិត្តណាស់ ។

ព្រោះតែសៃយីដាស់ហ្វាទីម៉ាស់سلام الله عليهاជាឧត្តមនារី បានជាព្រះសាស្តាﷺបានទទួលពាក្យសូមរៀបការជាមួយព្រះរាជបុត្រីព្រះអង្គﷺយ៉ាងច្រើន ពីសំណាក់ត្រកូលអ្នកមានស្តុកស្តម្ភនិងពួកមេដឹកនាំកុលសម្ព័ន្ធ ។ ព្រះអង្គﷺបានបដិសេធទាំងអស់ដោយថាព្រះអង្គﷺរង់ចាំព្រះរាជបញ្ជាអល់ឡោះហ៍عز وجل ។ អល់ឡោះហ៍عز وجلបានជ្រើសរើសអ៊ីម៉ាំអាលីصلوات الله عليه والسلامជាព្រះស្វាមីរបស់ព្រះនាងسلام الله عليها ព្រះអភិសេកក៏បានប្រព្រឹត្តឡើងឆ្នាំទី ២ សករាជហ៊ីជ្រ៉ោះត៍ ។ ព្រះអង្គទាំងពីរعليهم السلامបានព្រះរាជបុត្រ ៥ អង្គعليهم السلامគឺ៖ អ៊ីម៉ាំហាសាន់صلوات الله عليه والسلام, អ៊ីម៉ាំហ៊ូសៃន៍صلوات الله عليه والسلام, សៃយីដាស់ស៊ែណាប់سلام الله عليها, សៃយីដាស់ អ៊ុម គុលស៊ូមسلام الله عليها និងមុះហ្វាស៊ិនصلوات الله عليه والسلام ព្រះរាជទារកដែលសោយទិវង្គតកាលអ៊ូម៉ារបានវាយទ្វារផ្ទះព្រះនាងسلام الله عليها ធ្វើឲ្យព្រះនាងسلام الله عليهاរងរបួសធ្ងន់ ។

## លំហាត់ ១២

ចូរទន្ទេញអាយ៉ាស់ខាងក្រោមនេះឲ្យចាំ និងចូរសរសេរសម្រាយវានៅលើក្ដារ ឆ្នួន ។




តើស៊ូរ៉ោះត៍នេះឈ្មោះអ្វី មានលំដាប់លេខរៀងទីប៉ុន្មាននៅក្នុងព្រះគម្ពីរគូរអាន ?

---

---

---

តើ "អាប់តារ" មានន័យថាអ្វី ?

---

អល់ឡោះហ្ ﷻសន្យាអ្វីឲ្យព្រះសាស្ដា ﷺនៅក្នុងស៊ូរ៉ោះត៍នេះ ?

---

---

តើសៃយីដាស់ហ្វាទីម៉ាស់ ؑប្រសូតថ្ងៃទីប៉ុន្មាន ?

---

## មេរៀនទី ១៣

# ព្រះគម្ពីរគួរអានថែងអំពីសៃយីដាស់ ហ្វាទីម៉ាស់ អាស់-សាស់ររ៉ អ៊ុ ﷺ

១) នៅក្នុងស៊ូរ៉ោះត៏ អាល់-កៅស៊ារ - ព្រះរាជវង្សរបស់ព្រះសាស្ដា ﷺ ទៅជា កៅស៊ារ (សម្បូរ) ដោយបណ្ដាកូនចៅ ។

២) នៅក្នុងស៊ូរ៉ោះត៏ អាល់-អ៊ីនសាន អាយ៉ាស់ ៨-៩ គឺ៖

وَيُطْعِمُونَ الطَّعَامَ عَلَىٰ حُبِّهِ مِسْكِينًا وَيَتِيمًا وَأَسِيرًا ﴿٨﴾ إِنَّمَا نُطْعِمُكُمْ لِوَجْهِ اللَّهِ لَا نُرِيدُ مِنْكُمْ جَزَاءً وَلَا شُكُورًا ﴿٩﴾

*៨. ពួកគេបរិច្ចាគអាហារដើម្បីសេចក្ដីស្រឡាញ់ព្រះអង្គ ឲ្យទៅជនក្រីក្រ កូនកំព្រា និងជនជាប់ឃុំ ។ ៩. "យើងឲ្យអាហារនេះទៅអស់លោកដើម្បីគាប់ព្រះហឫទ័យ អល់ឡោះហ៍ទេ ។ យើងមិនទាមទាររង្វាន់ឬការដឹងគុណពីអស់លោកទេ។* (៧៦:៨-៩)

អាយ៉ាស់ពីរនេះជាការតបស្នងទឹកចិត្តទូលំទូលាយ និងការលះបង់របស់ សៃយីដាស់ហ្វាទីម៉ាស់ ﷺ និងសមាជិកគ្រួសារព្រះនាង ﷺ ក្នុងអំឡុងពេលដែល ព្រះអង្គទាំងអស់គ្នា عليهم السلام បានកាន់សីលត្រណមសច្ចា អាល់-ណាស៊ារ (النَّذْر) ដើម្បី សូមឲ្យអ៊ីម៉ាំហាសាន់ صلوات الله عليه والسلام និងអ៊ីម៉ាំហ៊ូសែន៍ صلوات الله عليه والسلام ជាពីជម្ងឺ ។

៣) នៅក្នុងស៊ូរ៉ោះត៏ អាស់ស៊ូរ៉ កាលពួកមុស្លីមចង់តបស្នងព្រះសាស្ដា ﷺ ដែលបានបម្រើអ៊ីស្លាម ។ ព្រះគម្ពីរគួរអានប្រាប់ព្រះអង្គ ﷺ ឲ្យឆ្លើយថា៖

قُل لَّآ أَسْـَٔلُكُمْ عَلَيْهِ أَجْرًا إِلَّا ٱلْمَوَدَّةَ فِى ٱلْقُرْبَىٰ ﴿٢٣﴾

*២៣. ...ចូរអ្នកថា៖ "ខ្ញុំមិនសូមឈ្នួលពីអស់លោកសម្រាប់អ្វីទាំងនេះទេ (គឺការផ្សាយការអប់រំ) សូមឲ្យតែអាណិតស្រឡាញ់បណ្ដាសាច់សាលោហិតជំនិតរបស់ ខ្ញុំ ។"*(៤២:២៣)

ពេលគេសួរព្រះអង្គ ﷺ ថា "សាច់សាលោហិតជំនិត" មានន័យថាអ្វី ។ ព្រះ អង្គ ﷺ មានព្រះវចនៈថា៖ "អាស់លុល-បៃត៍ عليهم السلام របស់ខ្ញុំ ﷺ ។"

អ្នកខ្លះប៉ុនប៉ងរាប់បញ្ចូលបណ្ដាមហេសីរបស់ព្រះសាស្ដាصلى الله عليه وآله وسلم ក្នុងអាស្ហ៊ុលុល-បៃត៍ដែរតែព្រះសាស្ដាصلى الله عليه وآله وسلمបានផ្ដោតទៅលើអ៊ីម៉ាំអាលីصلوات الله عليه والسلام សៃយីដ្ហាស្ហ៊ហ្វាទីម៉ាស្ហ៊سلام الله عليهاនិងព្រះសន្តអាអ៊ីម៉ាស្ហ៊عليهم السلامទេ ។ ភ័ស្តុតាងរឿងនេះនៅក្នុងហាឌីស្ហ អាល់-គីសាអ៊្ (حديث الكساء) ។

៤) នៅក្នុងស៊ូរ៉ោះត៍ អាល់-អាស្ហ៊ស្ហាប់ អាយ៉ាស្ហ៊ ៣៣ គឺ៖

ٱللَّهُ لِيُذْهِبَ عَنكُمُ ٱلرِّجْسَ أَهْلَ ٱلْبَيْتِ وَيُطَهِّرَكُمْ تَطْهِيرًا ﴿٣٣﴾

*៣៣. អល់ឡោះហ្ម៍គ្រាន់តែចង់ឲ្យពួកអ្នកចាកផុតពីមន្ទិល ជម្រះបន្សុទ្ធពួកអ្នកឲ្យបរិសុទ្ធជ្រះស្អាតតែប៉ុណ្ណោះទេ រាជកុលដ្ឋាន[របស់សាស្ដា]អើយ ។*(៣៣:៣៣)

ពេលព្រះសាស្ដាصلى الله عليه وآله وسلم សៃយីដ្ហាស្ហ៊ហ្វាទីម៉ាស្ហ៊سلام الله عليها អ៊ីម៉ាំអាលីصلوات الله عليه والسلام អ៊ីម៉ាំហាសាន់صلوات الله عليه والسلامនិងអ៊ីម៉ាំហ៊្វសៃន៍صلوات الله عليه والسلامបានជុំគ្នាក្នុងផ្ទះ ព្រះសាស្ដាصلى الله عليه وآله وسلمបានប្រកាសថា៖ "អល់ឡោះហ្ម៍عز وجلអើយ នេះគឺអាស្ហ៊លុល-បៃត៍عليهم السلامរបស់ទូលព្រះបង្គំជាខ្ញុំصلى الله عليه وآله وسلم ។" ខណៈនោះទេវតាយ៉ាប៊ីរអ៊ីលعليه السلامបានមកជាមួយអាយ៉ាស្ហ៊ខាងលើនេះ ។

៥) នៅក្នុងស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ាន អាយ៉ាស្ហ៊ ៦១ គឺ៖

فَقُلْ تَعَالَوْا۟ نَدْعُ أَبْنَآءَنَا وَأَبْنَآءَكُمْ وَنِسَآءَنَا وَنِسَآءَكُمْ وَأَنفُسَنَا وَأَنفُسَكُمْ ثُمَّ نَبْتَهِلْ فَنَجْعَل لَّعْنَتَ ٱللَّهِ عَلَى ٱلْكَـٰذِبِينَ ﴿٦١﴾

*៦១. ចូរអ្នកថា៖ "អស់លោកចូរមកចុះ យើងនឹងហៅកូនប្រុសៗរបស់យើងនិងកូនប្រុសៗរបស់អស់លោក បណ្ដាស្ត្រីរបស់យើងនិងបណ្ដាស្ត្រីរបស់អស់លោក ខ្លួនយើងផ្ទាល់និងខ្លួនអស់លោកផ្ទាល់ រួចហើយយើងបួងសួងយ៉ាងស្មោះអស់ពីចិត្ត សូមឲ្យព្រះបណ្ដាសារបស់អល់ឡោះហ្ម៍ពើបពះលើមុសាវាទី (គឺអ្នកនិយាយកុហក) ។"*(៣:៦១)

អាយ៉ាស្ហ៊នេះត្រូវដាក់ចុះមក ជាចម្លើយតបពួកកាន់សាសនាគ្រិស្តនៃស្រុកណាច់រ៉ន់ បបួលពួកគេធ្វើពិធីម៊ូបាហ្ហាឡាស្ហ៊ (الْمُبَاهَلَة) ។ ព្រះសាស្ដាصلى الله عليه وآله وسلمបាននាំអ៊ីម៉ាំហាសាន់صلوات الله عليه والسلامនិងអ៊ីម៉ាំហ៊្វសៃន៍صلوات الله عليه والسلامប្រៀបបាននឹង "កូនប្រុសៗ" របស់ព្រះអង្គصلى الله عليه وآله وسلم សៃយីដ្ហាស្ហ៊ហ្វាទីម៉ាស្ហ៊ប្រៀបបាននឹង "បណ្ដាស្ត្រី" របស់ព្រះអង្គصلى الله عليه وآله وسلم អ៊ីម៉ាំអាលីصلوات الله عليه والسلامប្រៀបបាននឹង "ខ្លួន" របស់ព្រះអង្គصلى الله عليه وآله وسلمផ្ទាល់" ។ លុះបានឃើញរង់មុខភ្លឺនៅ

ចំពោះមុខពួកគេ ពួកគ្រិស្តក៏បានបាត់បង់សេចក្ដីក្លាហាន ត្រឡប់ក្រោយវិញ ។

# លំហាត់ ១៣

ស៊ូរ៉ោះត៍ អាល់-កោស្ឫរថែងសំដៅទៅលើសៃយីដ្ហាស៊ុហ្វាទ៊ីម៉ាស៊ុ سلام الله عليها ។ ចូរសរសេរនៅក្នុងរូបផ្កាយ កន្លែងណាទៀតនៅក្នុងព្រះគម្ពីរគួរអានដែលនិយាយសំដៅទៅលើព្រះនាង عليهم السلام ដែរ ។



## មេរៀនទី ១៤

# អ៊ីដ្ទទាំងប្រាំ - អារម្ភកថា

អ៊ីដ្ទ (عيد) ជាពាក្យអារ៉ាប់មានន័យថាព្រឹត្តិការណ៍ដែលប្រព្រឹត្តទៅម្តងហើយម្តងទៀត ។ ក្នុងសាសនាអ៊ីស្លាម អ៊ីដ្ទជាពិធីបុណ្យរីករាយដែលមានរៀងរាល់ឆ្នាំ ។ ពាក្យអ៊ីដ្ទមាននៅក្នុងព្រះគម្ពីរគួរអាន ក្នុងស៊ូរ៉ោះត៊ុ អាល់-ម៉ាអ៊ីដាស៊ុ អាយ៉ាស៊ុ ១១៤ គឺ៖

قَالَ عِيسَى ٱبۡنُ مَرۡيَمَ ٱللَّهُمَّ رَبَّنَآ أَنزِلۡ عَلَيۡنَا مَآئِدَةً مِّنَ ٱلسَّمَآءِ تَكُونُ لَنَا عِيدًا لِّأَوَّلِنَا وَءَاخِرِنَا وَءَايَةً مِّنكَۖ وَٱرۡزُقۡنَا وَأَنتَ خَيۡرُ ٱلرَّٰزِقِينَ ١١٤

*១១៤. អ៊ីសា បុត្ររបស់ម៉ារយ៉ាំ បានទូល[ទៅកាន់អល់ឡោះហ្ទ៍]ថា៖ "អល់ឡោះហ្ទ៍ ព្រះម្ចាស់អស់ទូលព្រះបង្គំជាខ្ញុំអើយ សូមព្រះមេត្តាប្រទានចុះមកពីលើមេឃឲ្យអស់ទូលព្រះបង្គំជាខ្ញុំនូវអាហារ ដែលជាពិធីលៀង (បុណ្យ) ធំមួយសម្រាប់អស់ទូលព្រះបង្គំជាខ្ញុំ សម្រាប់អ្នកដំបូងបង្អស់និងសម្រាប់អ្នក ចុងក្រោយបង្អស់ក្នុងចំណោមអស់ទូលព្រះបង្គំជាខ្ញុំ ហើយជាសញ្ញាមួយដែលមកពីព្រះអង្គ ។ សូមព្រះអង្គមេត្តាប្រទានជីវព្រឹត្តឲ្យអស់ទូលព្រះបង្គំជាខ្ញុំ ព្រះអង្គជាអ្នកផ្តត់ផ្គង់ប្រសើរបំផុត ។"* (៥:១១៤)

អាយ៉ាស៊ុនេះបញ្ជាក់ប្រាប់យើងថា កាលព្រះសាស្តាអ៊ីសាﷺសុំអល់ឡោះហ្ទ៍ ﷻនូវអាហារសួគ៌ ព្រោះបណ្តាសាវកព្រះអង្គﷺចង់ឃើញភ័ស្តុតាងច្រើនដើម្បីបង្កើនជំនឿខ្លួននិងបានឃើញអព្ភូតហេតុអស្ចារ្យ និងដើម្បីធ្វើពិធីអបអរសាទរឱកាសនេះរៀងរហូតដោយសេចក្តីសោមនស្ស ។

សំណាងល្អយើងមានអ៊ីដ្ទប្រាំក្នុងមួយឆ្នាំគឺ៖

១) អ៊ីដ្ទ អ៊ុល-ឃ្ញុមអាស៊ុ

២) អ៊ីដ្ទ អ៊ុល-ហ្ញាជ្ជ៍

៣) អ៊ីដ្ទ អ៊ុល-ហ្វិត្រ៍

៤) អ៊ីដ្ទ អាល់-ក៊ុំដៀរ

៥) អ៊ីដ្ទ អាល់-មូបាហ្វាឡាស៊ុ

# លំហាត់ ១៤

ចូរសរសេរនៅលើនំខេក នូវពិធីបុណ្យទាំងប្រាំដែលយើងអបអរសាទររាល់ឆ្នាំ ។



ពាក្យ "អ៊ីដូ" មានន័យថាអ្វី ?

---

---

តើពាក្យ "អ៊ីដូ" មាននៅត្រង់ណាក្នុងព្រះគម្ពីរគួរអាន តើអាយ៉ាស់នេះថែងអំពីអ្វី ?

---

---

## មេរៀនទី ១៥

# អ៊ីដុ អ៊ុល-យ៉ុមអាត់

យ៉ុមអាត់គឺថ្ងៃសុក្រ សម្រាប់មុស្លីមទាំងអស់ជាថ្ងៃសីលសំខាន់ណាស់ ។ ព្រះសាស្តាﷺមានព្រះវចនៈថា៖ "២៤ ម៉ោងយប់និងថ្ងៃរបស់ថ្ងៃសុក្រជាកម្មសិទ្ធិរបស់អល់ឡោះហ៍ ។ គ្រប់ពេលវេលា មាន ៦០០ ០០០ ឱកាសសម្រាប់ដោះខ្លួនឲ្យរួចផុតពីភ្លើងនរក ។" នៅក្នុងប្រក្រតិទិនអ៊ីស្លាម យប់មកដល់មុនថ្ងៃ ដូច្នេះថ្ងៃសុក្រចាប់ផ្តើមពីពេលស្វ៍ឡាត់ម៉ាក់រិប (ពេលថ្ងៃលិច) ថ្ងៃព្រហស្បតិ៍ (ពោលគឺ ថ្ងៃព្រហស្បតិ៍យប់) ។

មានអាម៉ាល់មួយចំនួនដែលគប្បីធ្វើក្នុងថ្ងៃយ៉ុមអាត់ (ស៊ូណាត់) ។ សម្រាប់យប់យ៉ុមអាត់ (គឺយប់ថ្ងៃព្រហស្បតិ៍) គឺ៖

១-គិតដល់បណ្ដាអ្នកស្លាប់របស់យើង (មិត្តយើង គ្រួសារយើងដែលបានត្រឡប់ទៅរកអល់ឡោះហ៍វិញ) ។

២-សូត្រស៊ូរ៉ោះត៍ យ៉ាស៊ីន ។

៣-សូត្រឌូអាអ៊ំគូម៉ៃល៍ ។

៤-សិក្សាអ៊ីស្លាមប្រការនីមួយ ។

សម្រាប់ថ្ងៃយ៉ុមអាត់ (គឺថ្ងៃសុក្រ) គឺ៖

១-ងូតទឹកយ៉ុមអាត់ (គុស៊ូលយ៉ុមអាត់) ។

២-កាត់ក្រចក ស្លៀកពាក់ស្អាត លាបទឹកអប់ (ព្រោះជាថ្ងៃអ៊ីដុ) ។

៣-ទៅមើលផ្ទះបុគ្គលជាទីស្រឡាញ់របស់យើង ។

៤-ធ្វើស្វ៍ឡាត់ យ៉ុមអាត់ (រួមគ្នា) ។

៥-សិក្សាអ៊ីស្លាមប្រការនីមួយ ។

## លំហាត់ ១៥

ថ្ងៃណា អ៊ីដូ អ៊ុល-យ៉ូមអាស្ទូ ?

---

ចូរសរសេរនៅលើរូបដៃនូវអាម៉ាល់ដែលគប្បីធ្វើពេលយ៉ូមអាស្ទូ ។

សម្រាប់យប់យ៉ូមអាស្ទូ គឺៈ



សម្រាប់ថ្ងៃយ៉ូមអាស្ទូ គឺៈ



# មេរៀនទី ១៦

## អ៊ីដុ អ៊ុល-ហាច់

គេហៅ អ៊ីដុ អ៊ុល-ហាច់ ថា អ៊ីដុ អ៊ុល-អាដ្ហា (عيد الأضحى) ដែរ (បុណ្យពលីកម្ម)។ អ៊ីដុ អ៊ុល-ហាច់ប្រព្រឹត្តទៅក្នុងថ្ងៃទី ១០ ខែចុងក្រោយបង្អស់នៃប្រក្រតិទិនអ៊ីស្លាម (ខែ ស៊ុល-ហ៊ីច្ចយ៉ាស់ (ذُو ٱلْحِجَّة))។ បុណ្យនេះបញ្ជាក់ថាពិធីហាច់នៅម៉ាក់កាស់របស់បណ្ដាមុស្លីមបានចប់ស្រេច។ ជាការរំលឹកដល់ព្រះសាស្ដាអ៊ីបរ៉ហ៊ីម﵇ដែលបានធ្វើពលីកម្មជីវិតព្រះរាជបុត្រព្រះអង្គ﵇ ព្រះសាស្ដាអ៊ីសម៉ាអ៊ីល﵇។ កាលព្រះសាស្ដាអ៊ីសម៉ាអ៊ីល﵇មានព្រះជន្ម ១៣ ឆ្នាំ ព្រះសាស្ដាអ៊ីបរ៉ហ៊ីម﵇សុបិនឃើញ ថាព្រះអង្គ﵇បានបូជាជីវិតកូនប្រុសព្រះអង្គ﵇។ កាលនោះគឺថ្ងៃទី ៨ ស៊ុល ហ៊ីច្ចយ៉ាស់ គេហៅថ្ងៃនោះដែរថា យ៉ៅម៉ាល់-តាររវីយ៉ាស់ (يَوْمَ التَّرْوِيَةِ ថ្ងៃសុបិនដំបូង)។

ព្រះសាស្ដាអ៊ីបរ៉ហ៊ីម﵇ តែងតែបានទទួលព្រះរាជបញ្ជាពីអល់ឡោះហ្ជ៏ ﷿ ក្នុងសុបិន តែព្រោះតែគេឲ្យព្រះអង្គ﵇សម្លាប់កូនឯងបានជាព្រះអង្គ﵇នឹកក្នុងចិត្តថាតើសុបិននេះពិតឬទេ។ ថ្ងៃបន្ទាប់ព្រះអង្គ﵇សុបិនដដែល ពេលនោះទើបព្រះអង្គ﵇ជឿជាក់ថាសុបិននោះជាព្រះរាជបញ្ជាពិតប្រាកដ។ ដូច្នេះឯងបានជាគេហៅថ្ងៃទី ៩ ស៊ុល ហ៊ីច្ចយ៉ាស់ថា យ៉ៅម៉ាល់-អារ៉ហ្វាស់ (يَوْمَ الْعَرَفَةِ ថ្ងៃដឹងច្បាស់)។

ព្រះគម្ពីរគួរអានចែងនៅក្នុងស៊ូរ៉ោះត៍ អាស្ស-ស្វហ្វហ្វាត អាយ៉ាស់ ១០២ ថា៖

فَلَمَّا بَلَغَ مَعَهُ ٱلسَّعْىَ قَالَ يَٰبُنَىَّ إِنِّىٓ أَرَىٰ فِى ٱلْمَنَامِ أَنِّىٓ أَذْبَحُكَ فَٱنظُرْ مَاذَا تَرَىٰ ۚ قَالَ يَٰٓأَبَتِ ٱفْعَلْ مَا تُؤْمَرُ ۖ سَتَجِدُنِىٓ إِن شَآءَ ٱللَّهُ مِنَ ٱلصَّٰبِرِينَ ﴿١٠٢﴾

*១០២. លុះគេ (អ៊ីសម៉ាអ៊ីល) មានអាយុអាចប្រកបកិច្ចការជាមួយគេបានហើយ គេបានថា៖ "កូនឪពុកអឺយ ឪពុកបានសុបិនឃើញឪពុកកំពុងតែសំឡេះកូនដើម្បីធ្វើពលីទាន។ តើកូនយល់ឃើញយ៉ាងណា?" គេបានថា៖ "លោកឪពុក សូមលោកឪពុកធ្វើតាមអ្វីដែលគេបានបញ្ជាឲ្យលោកឪពុកធ្វើទៅ។ បើអល់ឡោះហ្ជ៏ទ្រង់ប្រាថ្នា លោកឪពុកនឹងឃើញថាកូនជាម្នាក់ក្នុងចំណោមអ្នកអត់ធ្មត់[នៅលើមាគ៌ាអល់ឡោះហ្ជ៏]។"*(៣៧:១០២)

ដូច្នេះ ព្រះសាស្តាអ៊ីបរ៉ហ៊ីម﵇ក៏បាននាំកូនទៅកន្លែងរហោឋាន គ្មានមនុស្សនៅ ។ តាមផ្លូវ ស្ទៃតនលعنه اللهបានក្លែងខ្លួនជាមនុស្សចាស់មកល្បួងទាក់ទាញចិត្តព្រះសាស្តាអ៊ីបរ៉ហ៊ីម﵇ថាព្រះអង្គ﵇កំពុងតែធ្វើខុសដោយសម្លាប់កូនឯង ។ ស្ទៃតនលعنه اللهបានមករកព្រះអង្គ﵇បីដង រាល់ៗដងព្រះសាស្តាអ៊ីបរ៉ហ៊ីម﵇ដេញវាលعنه اللهដោយគ្រវែងវាលعنه اللهនឹងដុំថ្ម ៧ ដុំ ។ លុះបានទៅដល់មីណា ព្រះសាស្តាអ៊ីបរ៉ហ៊ីម﵇ឲ្យកូនដេកលើដី ទាញយកកាំបិតសំដៅកកូន ។ ព្រះសាស្តាអ៊ីសម៉ាអ៊ីល﵇ឃើញឪពុកពិបាកចិត្តខ្លាំងដែលត្រូវសម្លាប់កូនឯងនោះ ក៏បានថា៖ "លោកឪពុកអើយ ចូរចងដៃចងជើងកូនដើម្បីកុំឲ្យកូនរើរួច ។ ចងក្រណាត់បិទភ្នែកលោកឪពុកទៅដើម្បីកុំឲ្យមើលឃើញកូនស្លាប់ ។ សំលៀងកាំបិតឲ្យមុតដើម្បីប្រតិបត្តិការឆាប់ចប់ ។ ដូច្នេះកូននឹងមិនឈឺចាប់ទេ ។" ព្រះសាសាអ៊ីបរ៉ហ៊ីម﵇ក៏បានធ្វើដូចកូនប្រាប់ បន្ទាប់មកបានអារកកូនព្រះអង្គ﵇ ។ តែពេលព្រះអង្គ﵇បើកក្រណាត់បិទភ្នែកចេញ ព្រះអង្គ﵇ភ្ញាក់ព្រើតដោយឃើញកូនព្រះអង្គ﵇គ្មានរបួស ឈរក្បែរព្រះអង្គ﵇ ហើយឃើញថាព្រះអង្គ﵇បានសំឡែះបាពពែជាជំនួសវិញ ។

អល់ឡោះហ្ ﷻបានធ្វើឲ្យទង្វើទាំងអស់របស់ព្រះសាស្តាអ៊ីបរ៉ហ៊ីម﵇ និងទង្វើទាំងអស់របស់ព្រះរាជវង្សព្រះអង្គ﵇ទៅជាវ៉ាយិបសម្រាប់មុស្លីមទាំងអស់ ។

ការធ្វើពលីកម្មសត្វជាដំណាក់កាលចុងក្រោយបង្អស់នៃពិធីហាជ្ជ៍ គេហៅពិធីហាជ្ជ៍ដែរថា អ៊ីដ្ទ អ៊ុល-អាដ្ហ៍ហា (អ៊ីដ្ទពលីកម្ម) ។ នេះជាឱកាសរីករាយព្រោះយើងសង្ឃឹមថាគេនឹងព្រមទទួលយកពិធីហាជ្ជ៍របស់យើង ហើយនេះជាការចាប់ផ្តើមថ្មីដោយបានទទួលការលុបលាងបាបនានារបស់យើង ។

# លំហាត់ ១៦

ចូរឆ្លើយសំណួរខាងក្រោមនេះ ។

១-ព្រះសាស្តាដែលត្រូវនាំខ្លួនទៅធ្វើពលីកម្មអ៊ីដ្ និ អុល-ហ្កាឌ់នោះមានព្រះនាមអ្វី ?

២-គេហៅថ្ងៃសុបិនដំបូងថាថ្ងៃអ្វី ជាភាសាអារ៉ាប់ ?

៣-តើគេធ្វើពិធីបុណ្យ អ៊ីដ្ និ អុល-ហ្កាឌ់ ក្នុងខែណា ?

៤-តើពលីកម្មត្រូវធ្វើនៅកន្លែងណា ?

៥-តើពិធីបុណ្យអ៊ីដ្ និ អុល-ហ្កាឌ់មានឈ្មោះមួយទៀតថាអ្វី ?

៦-ឪពុករបស់ព្រះសាស្តាដែលត្រូវនាំខ្លួនទៅបូជានោះឈ្មោះអ្វី ?

៧-តើអ៊ីដ្ និ នេះបញ្ជាក់ថាអ្វីបានចប់ស្រេច ?

៨-អ្នកណាព្យាយាមទាក់ទាញព្រះសាស្តាឲ្យវង្វេងចេញពីផ្លូវទៅធ្វើពលីកម្ម ?

៩-គេហៅថ្ងៃដឹងច្បាស់ថាអ្វីជាភាសាអារ៉ាប់ ?

១០-គេឃើញមានអ្វីជាជំនួសព្រះសាស្តា ?

១១-អ៊ីដ្ និ អុល-ហ្កាឌ់គឺថ្ងៃទី.......ខែ ហ្ស៊ុល-ហ៊្ជិច្ចយ៉ាស្ ។

# មេរៀនទី ១៧

## អ៊ីដុ អ៊ុល-ហ្វីត្ទ័រ

អ៊ីដុ អ៊ុល-ហ្វីត្ទ័រ (عِيدُ الْفِطْرِ) ជាពិធីបុណ្យចប់បួជនីយខែរ៉ម៉ាដ្ធន គឺថ្ងៃទី ១ ខែស្ស៊ៅវ៉ាល់ (شَوَّال) ។

ហ្វីត្ទ័រ មានន័យថា "ផ្តាច់" ដូច្នេះពិធីបុណ្យនេះបញ្ជាក់នូវការបញ្ចប់អំឡុងពេលកាន់សីលត្រណម ។ អ៊ីដុ អ៊ុល-ហ្វីត្ទ័រជាឱកាសរីករាយព្រោះយើងបានចំណាយពេលមួយខែនេះកាន់សីលត្រណម ចៀសវាងទង្វើហារ៉ាំ ចៀសវាងបាយនិងទឹក ក្នុងពេលថ្ងៃ ។ ដូច្នេះយើងបានលត់ដំខ្លួនឲ្យចេះរស់នៅដោយពុំធ្វើទង្វើហារ៉ាំ ។ ជាឱកាសរីករាយដែរព្រោះយើងសង្ឃឹមថាគេព្រមទទួលយកការបួងសួងទាំងអស់របស់យើង ថាគេនឹងលុបលាងបាបមុនៗរបស់យើង យើងនឹងបានចាប់ផ្តើមសាថ្មី ។ ក្នុងអំឡុងខែរ៉ម៉ាដ្ធនយើងគិតដល់ជនក្រីក្រដែលនៅតែស្រេកឃ្លានទោះបីខែរ៉ម៉ាដ្ធនកន្លងផុតទៅហើយក៏ដោយព្រោះតែខ្វះខាតអាហារ ពេលយើងកាន់សីលត្រណម យើងត្រេកអរចំពោះព្រះអំណោយដែលអល់ឡោះហ្វ៍ﷻបានប្រទានឲ្យយើង យើងពេញចិត្តនឹងចែករំលែកព្រះអំណោយទាំងនេះ ។

ដើម្បីពង្រឹងទ្រឹស្តីនេះនៅក្នុងអារម្មណ៍យើង អល់ឡោះហ្វ៍ﷻបានដាក់វ៉ាយិ៊បឲ្យចេញស្ក៉ាកាត់ អ៊ុល ហ្វីត្ទ័រនៅពេលចប់ខែរ៉ម៉ាដ្ធន ។

# លំហាត់ ១៧

អ៊ីដូ អ៊ុល-ហ្វីត្រ៍នៅក្រោយខែរ៉ម៉ាដូន ។ ចូរសរសេរនៅលើរូបអវយវៈនីមួយៗខាងក្រោមនេះទង្វើដែលអ្នកមិនត្រូវធ្វើជាមួយអវយវនោះ ជាពិសេសក្នុងពេលកាន់សីលត្រណម ។











# មេរៀនទី ១៨

## អ៊ីដុ អាល់-ក៏ដៀរ

ថ្ងៃទី ១៨ ស៊ុល ហ៊ីច្ចយ៉ាស់ ទេវតាយីបរ៉អ៊ីលﷺបាននាំអាយ៉ាស់មួយក្នុងស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស់ មកឲ្យព្រះសាស្តាﷺ គឺ៖

۞يَـٰٓأَيُّهَا ٱلرَّسُولُ بَلِّغۡ مَآ أُنزِلَ إِلَيۡكَ مِن رَّبِّكَۖ وَإِن لَّمۡ تَفۡعَلۡ فَمَا بَلَّغۡتَ رِسَالَتَهُۥۚ وَٱللَّهُ يَعۡصِمُكَ مِنَ ٱلنَّاسِۗ ﴿٦٧﴾

*៦៧. សាស្តាអឺយ ចូរអ្នកផ្សព្វផ្សាយអ្វីដែលគេបានបើកឲ្យអ្នកដឹងមកពីព្រះម្ចាស់អ្នក ។ បើអ្នកមិនធ្វើ[ការផ្សព្វផ្សាយនោះ]ទេ[ព្រោះខ្លាចមនុស្សកំណាច វាដូចជា]អ្នកពុំបានផ្សព្វផ្សាយ[ប្រាប់មនុស្សជាតិ] នូវព្រះរាជសាររបស់ព្រះអង្គទេ ។ អល់ឡោះហ្វ៍នឹងការពារអ្នកទល់បណ្តាមនុស្ស ។* (៥:៦៧)

ព្រោះតែព្រះសាស្តាﷺគោរពព្រះរាជបញ្ជាដ៏សំខាន់នេះ បានជាព្រះអង្គﷺមកឈប់នៅឯកន្លែងមួយដែលគេហៅថា ក៏ដៀរ ឃុម (غَدِيرَ خُمٍّ បឹងឃុម) ។ ព្រះអង្គﷺបានប្រាប់ឲ្យគេវាតកន្លែងមួយធ្វើវេទិកាដោយកែបអូដ្ឋ ។ ព្រះអង្គﷺបានឲ្យប៊ីឡាល់ ដែលមានសម្លេងខ្លាំង ប្រកាសហៅមនុស្សដែលនៅឆ្ងាយពីកន្លែងនោះនិងបណ្តាអ្នកដែលនៅក្រោយគេ ។

កាលនោះដល់ម៉ោងថ្ងៃត្រង់ ថ្ងៃកំពុងក្តៅខ្លាំងណាស់ ។ ព្រះសាស្តាﷺបានដឹកនាំស្វ៍ឡាត់ រួចហើយបានឡើងលើវេទិកាដើម្បីនឹងឲ្យទាំងអស់គ្នាមើលឃើញព្រះអង្គﷺ ។ បន្ទាប់មកព្រះអង្គﷺថ្លែងសុន្ទរកថា មួយប៉ែកនៃសុន្ទរកថានោះមានដូចតទៅគឺ៖ "ប្រជារាស្ត្រអឺយ ខ្ញុំﷺទុកឲ្យអស់លោកនូវកេរមរតកដ៏មានតម្លៃពីរគឺ៖ ព្រះគម្ពីរអល់ឡោះហ្វ៍عزّ وجلّនិងកូនចៅខ្ញុំﷺ អាស្ល៍លុល-បៃត៍عليهم السلام ។ ទាំងពីរនេះនឹងមិនបែកគ្នាជាដាច់ខាត លុះត្រាទាំងអស់គ្នានេះនឹងបានមកជួបខ្ញុំﷺវិញឯឋានសួគ៌នាអាល់-កៅស្ញ័រ ។ ដរាបណាអស់លោកនៅជាប់ជាមួយកេរមរតកទាំងពីររបស់ខ្ញុំﷺនេះ ដរាបនោះអស់លោកនឹងមិនល្មៀងចេញពីផ្លូវល្អជាដាច់ខាត អត់ពីខ្ញុំﷺទៅ ។" បន្ទាប់មកព្រះសាស្តាﷺបានសួរបណ្តាអ្នកស្តាប់ថា៖ "ប្រជារាស្ត្រអឺយ ខ្ញុំﷺមានអំណាចជាងគេលើអស់លោកជាងខ្លួនអស់លោកទៅទៀតមែនទេ ?" ទាំងអស់គ្នានៅទីនោះបានតបថា៖ "មែន ព្រះសាស្តាﷺអល់ឡោះហ្វ៍عزّ وجلّអឺយ !" រួចហើយព្រះ

សាស្ដាﷺបានចាប់ដៃអ៊ីម៉ាំអាលីؑលើកឡើង បង្ហាញហ្វូងមនុស្សគ្រប់ជ្រុងវេទិកា ហើយមានព្រះវចនៈថា៖ "مَنْ كُنْتُ مَوْلَاهُ فَهٰذَا عَلِيٌّ مَوْلَاهُ" អ្នកណាក៏ដោយដែលមានខ្ញុំﷺជាម្ចាស់ អាលីؑក៏ជាម្ចាស់របស់អ្នកនោះដែរ ។" បន្ទាប់មកព្រះអង្គﷺបានលើកដៃឡើងលើហើយបួងសួងថា៖ "អល់ឡោះហ្ទ៍ﷻអើយ សូមព្រះអង្គﷺទ្រង់សព្វព្រះហឫទ័យអ្នកណាដែលស្រឡាញ់អាលីؑ សូមព្រះអង្គﷺស្អប់អ្នកណាដែលមិនស្រឡាញ់គេؑ ។" ព្រះអង្គﷺប្រកាសដូចនេះបីដង ហើយចុះពីលើវេទិកា ។ ពេលនោះទេវតាយ៉ិបរ៉អ៊ីលؑចុះមកជាមួយអាយ៉ាស្ទ័ស្ទីវ៉េះត្ទ័ អាល់-ម៉ាអ៊ីដាស្ទ័នេះគឺ៖

ٱلْيَوْمَ أَكْمَلْتُ لَكُمْ دِينَكُمْ وَأَتْمَمْتُ عَلَيْكُمْ نِعْمَتِي وَرَضِيتُ لَكُمُ ٱلْإِسْلَٰمَ دِينًاۚ ۝٣

*៣. ថ្ងៃនេះអញបានធ្វើឲ្យសាសនាពួកអ្នកសុក្រឹតឥតខ្ចោះសម្រាប់ពួកអ្នក បានបង្គ្រប់ឧបការធម៌អញលើពួកអ្នក ហើយអញបានជ្រើសយកអ៊ីស្លាមជាសាសនាសម្រាប់ពួកអ្នក ។* (៥:៣)

ព្រះសាស្ដាﷺបានអរព្រះគុណអល់ឡោះហ្ទ៍ﷻដែលបានប្រោសមេត្តា ហើយព្រះអង្គﷺបានឲ្យអ៊ីម៉ាំអាលីؑអង្គុយនៅក្នុងជំរំសំពត់មួយ ដើម្បីនឹងឲ្យគេមកចាប់ដៃព្រះអង្គﷺនិងសម្ដែងសេចក្ដីអបអរសាទរសរសើរព្រះអង្គؑ ។ ក្នុងចំណោមមនុស្សដែលបានអបអរសាទរសរសើរអ៊ីម៉ាំអាលីؑមុនគេ ដែលព្រះអង្គؑបានទទួលតំណែងនោះ មាន អាប៊ូ បាការ និង អ៊ូម៉ារ ។ អ្វីដែលចម្លែកនោះគឺទាំងពីរនាក់នេះ ជាបុគ្គលដំបូងបង្អស់ដែរដែលបានឆក់យកសិទ្ធិព្រះអង្គؑបន្ទាប់ពីព្រះសាស្ដាﷺបានចូលទិវង្គត ។

ថ្ងៃនេះគឺថ្ងៃទី ១៨ ស៊ុល ហ៊ីច្ចយ៉ាស្ទ័ ដែលគេហៅថា អ៊ីដ្ទ អាល់-ក៏ដៀរ (عِيدَ الْغَدِيرِ) ។

## លំហាត់ ១៨

ចូរសរសេរអត្ថន័យរបស់ពាក្យពេជន៍នៅលើក្តារឆ្នួនខាងក្រោមនេះ ហើយចូរទន្ទេញឲ្យចាំ ។




តើព្រះសាស្តាﷺបានថ្លែងពាក្យពេជន៍ខាងលើនេះពេលណា ហេតុអ្វី ?

.............................................................................................................

.............................................................................................................

តើព្រះសាស្តាﷺបានថាអ្វីទៀតថ្ងៃនេះអំពីគួរអាននិងអាស្ហលុល-បៃត៏عليهم السلام ?

.............................................................................................................

.............................................................................................................

## មេរៀនទី ១៩

### អ៊ីដុ អាល់-មូបាហាឡាស់ (المُباهَلَة)

ព្រះសាស្ដាﷺបានផ្ញើសំបុត្រទៅមេដឹកនាំប្រទេសនានា សូមឲ្យចូលសាសនាអ៊ីស្លាម ។ គេបានផ្ញើសំបុត្រនេះដែរទៅឲ្យពួកគ្រិស្តសាសនិកនៃនគរណាជ្ញ៉រ៉ន់ ។ ពេលបានទទួលសំបុត្រពួកគេសម្រេចចិត្តមកជួបព្រះសាស្ដាﷺ ។ ក្រុមគ្រិស្តសាសនិកបានមកដល់ម៉ាឌីណាស់ ចូលក្នុងម៉ាស់ជ្ជិដដោយស្លៀកពាក់សូត្រ ពាក់ក្រវិលមាស ពាក់ខ្សែកបន្តោងរូបឈើឆ្កាង ។ ពេលឃើញពួកគេស្លៀកពាក់បែបនេះព្រះសាស្ដាﷺមិនចូលចិត្តទេ ព្រះអង្គﷺមិនអើពើពួកគេទេ ។ ពួកគេដឹងថាមានបញ្ហាតែមិនដឹងធ្វើអ្វី ។ ធ្វើតាមយោបល់របស់អ៊ីម៉ាំអាលីصلوات الله عليه والسلام ពួកគេបានផ្លាស់សំលៀកបំពាក់មកស្លៀកពាក់ធម្មតាវិញ បានដោះគ្រឿងអលង្ការចេញ ។ រួចហើយពួកគេត្រឡប់ទៅជួបព្រះសាស្ដាﷺវិញ ព្រះសាស្ដាﷺបានទទួលពួកគេយ៉ាងកក់ក្ដៅ ។ មុនចាប់ផ្ដើមសន្ទនា ពួកគេសូមអនុញ្ញាតសូត្របួងសួង គេក៏បានយល់ព្រម ។ រួចហើយកិច្ចសន្ទនាក៏បានចាប់ផ្ដើម ពួកអ្នកស្រុកណាជ្ញ៉រ៉ន់មិនចង់ស្ដាប់ព្រះសាស្ដាﷺទេ ថាពួកគេជឿព្រះសាស្ដាអ៊ីសាعليه السلامជាព្រះរាជបុត្ររបស់ព្រះ ព្រោះព្រះអង្គعليه السلامមិនមានឪពុក ។ ខណៈនោះ ទេវតាជ្ញីបរ៉អ៊ីលعليه السلامបាននាំអាយ៉ាស់គួរអាន ស៊ូរ៉ោះតុ៍ អាលី អ៊ីមរ៉ន មកគឺ៖

إِنَّ مَثَلَ عِيسَىٰ عِندَ ٱللَّهِ كَمَثَلِ ءَادَمَ ۖ خَلَقَهُۥ مِن تُرَابٍ ثُمَّ قَالَ لَهُۥ كُن فَيَكُونُ ﴿٥٩﴾

*៥៩. សម្រាប់អល់ឡោះហ៍ អ៊ីសាប្រៀបបាននឹងអាដាំ ។ ព្រះអង្គបានបង្កើតគេ (គឺអាដាំ) មកពីធូលី បន្ទាប់ពីនោះព្រះអង្គមានព្រះតម្រាស់ចំពោះគេថា៖ "ចូរកើតឡើង ។" គេក៏បានកើតឡើង ។*(៣:៥៩)

បានសេចក្ដីថា ដែលគេអាចហៅព្រះសាស្ដាអ៊ីសាعليه السلامបានថាកូនរបស់ព្រះ ព្រោះតែព្រះអង្គعليه السلامកើតមកដោយពុំមានឪពុកនោះ ព្រះសាស្ដាអាដាំعليه السلامមានសិទ្ធិឲ្យគេហៅព្រះអង្គعليه السلامថាកូនព្រះជាងព្រះសាស្ដាអ៊ីសាعليه السلامទៅទៀត ព្រោះព្រះសាស្ដាអាដាំعليه السلامបានកើតមកដោយពុំមានឪពុកនិងពុំមានម្ដាយ ។ ពួកកាន់សាសនាគ្រិស្តឆ្លើយតបពាក្យសំអាងនេះមិនរួចទេ តែពួកគេនៅតែជជែកទាំង

ចចេស ។

បន្ទាប់មកអាយ៉ាស់ត្ឫរអានខាងក្រោមនេះត្រូវដាក់មក (ស៊ូរ៉ោះត៍ អាលី អ៊ីមរ៉ន អាយ៉ាស់ ៦១) គឺ៖

فَمَنْ حَآجَّكَ فِيهِ مِنۢ بَعْدِ مَا جَآءَكَ مِنَ ٱلْعِلْمِ فَقُلْ تَعَالَوْا۟ نَدْعُ أَبْنَآءَنَا وَأَبْنَآءَكُمْ وَنِسَآءَنَا وَنِسَآءَكُمْ
وَأَنفُسَنَا وَأَنفُسَكُمْ ثُمَّ نَبْتَهِلْ فَنَجْعَل لَّعْنَتَ ٱللَّهِ عَلَى ٱلْكَٰذِبِينَ ﴿٦١﴾

*៦១. ដូច្នេះអ្នកណាមួយឈ្លោះប្រកែកជាមួយអ្នកអំពីរឿងនេះ ក្រោយពីព្រះអភិញ្ញាបានមកដល់អ្នកហើយនោះ ចូរអ្នកថា៖ "អស់លោកចូរមកចុះ យើងនឹងហៅកូនប្រុសៗរបស់យើងនិងកូនប្រុសៗរបស់អស់លោក បណ្ដាស្ត្រីរបស់យើងនិងបណ្ដាស្ត្រីរបស់អស់លោក ខ្លួនយើងផ្ទាល់និងខ្លួនអស់លោកផ្ទាល់ រួចហើយយើងបួងសួងយ៉ាងស្មោះអស់ពីចិត្ត សូមឲ្យព្រះបណ្ដាសារបស់អល់ឡោះហ៍ពើបពះលើមុសាវាទី (គឺអ្នកនិយាយកុហក) ។"* (៣:៦១)

ព្រះសាស្ដាﷺបានបង្ហាញអាយ៉ាស់នេះដល់ពួកកាន់សាសនាគ្រិស្ត ហើយបានប្រកាសបបួលធ្វើ "មូបាហ៊្វាឡាស់" មានន័យថាដាក់បណ្ដាសាគ្នាទៅវិញទៅមក ។ ពួកគ្រិស្តសាសនិកយល់ព្រម ។

ស្អែកឡើង ថ្ងៃទី ២៤ ស៊្មុល ហ៊ីច្ជ៉ាស់ ឆ្នាំ ៩ សករាជហ៊្ចិច្ជរ៉ោះត៍ ព្រះសាស្ដាﷺបានចេញទៅធ្វើ "មូបាហ៊្វាឡាស់" ។ ព្រះអង្គﷺពអ៊ីមុាំហ៊ូសៃន៍صلوات الله عليه والسلام ដឹកដៃអ៊ីមុាំហាសាន់صلوات الله عليه والسلام ។ សៃយីដ្វាស់ហ្វាទីម៉ាស់سلام الله عليهاដើរពីក្រោយព្រះអង្គﷺ អ៊ីមុាំអាលីصلوات الله عليه والسلامដើរពីក្រោយព្រះនាងسلام الله عليها ។ ព្រះសាស្ដាﷺបានប្រាប់អាស់ហ្ញុល-បៃត៍عليهم السلامព្រះអង្គﷺថា៖ "ពេលខ្ញុំﷺសូត្រអ្នកទាំងអស់គ្នាعليهم السلامចូរថាអាមីន ។" គោរពតាមអាយ៉ាស់ មូបាហ៊្វាឡាស់ ដែលអល់ឡោះហ៍عزّ وجلّបានដាក់មកនោះ ព្រះសាស្ដាﷺបាននាំអ៊ីមុាំហាសាន់صلوات الله عليه والسلامនិងអ៊ីមុាំហ៊ូសៃន៍صلوات الله عليه والسلامមកជា "កូនប្រុសៗ" របស់ព្រះអង្គﷺ សៃយីដ្វាស់ហ្វាទីម៉ាស់سلام الله عليهاជា "ស្ត្រី" របស់ព្រះអង្គﷺ អ៊ីមុាំអាលីصلوات الله عليه والسلامជា "ខ្លួន" របស់ព្រះអង្គﷺ ។ ពេលពួកគ្រិស្តសាសនិកបានឃើញវង់មុខដ៏ភ្លឺស្អាតនៅពីមុខខ្លួន ពួកគេញ័រខ្លួនទទ្រើត នៅមិនស្ងៀមទេ ។ ពួកគេដកថយ ដឹងខ្លួនថាចាញ់គេ ។

# លំហាត់ ១៩




ដើម្បីធ្វើមូបាហាឡាស់ ព្រះសាស្តា ﷺ បានចេញទៅជាមួយបុគ្គលខាងក្រោមនេះ ហេតុអ្វី ? បុគ្គលទាំងនោះជាអ្នកណា ?

..........................................................................................................................

..........................................................................................................................

មូបាហាឡាស់បានប្រព្រឹត្តឡើងថ្ងៃណា ?

..........................................................................................................................

..........................................................................................................................

លទ្ធផលចុងក្រោយដូចម្តេច ?

..........................................................................................................................

# មេរៀនទី ២០

## ឈ្មោះខែអ៊ីស្លាម

ក្នុងសាសនាអ៊ីស្លាមយើងតាមប្រក្រតិទិនចន្ទគតិ (ខែ) ផ្ទុយពីប្រក្រតិទិនសុរិយគតិ (គ្រិស្ត)។ តាមប្រក្រតិទិនចន្ទគតិបានសេចក្ដីថាយកទ្រង់ទ្រាយរបស់ខែមកប្រើដើម្បីនឹងដឹងថ្ងៃ។ ខែផ្លាស់ប្ដូរទ្រង់ទ្រាយ។ ដំបូងវាភ្លឺតែមួយចំណិតតូចណាស់ដែលស្ទើរតែមើលមិនឃើញ (ខ្នើតខែថ្មី) នេះគឺថ្ងៃទីមួយរបស់ខែ។ បន្ទាប់មកខែកាន់តែធំឡើងៗលុះពេញរង់មូល នេះគឺពាក់កណ្ដាលខែ (ថ្ងៃទី ១៤ របស់ខែ)។ បន្ទាប់មកទៀតខែចាប់ផ្ដើមទៅជាតូចទៅៗ លុះគេមិនអាចមើលឃើញ នេះគឺចុងខែ។ ខែត្រូវប្រើពេល ២៩ ឬ ៣០ ថ្ងៃដើម្បីឆ្លងកាត់ដំណាក់កាលទាំងអស់របស់វា។ ដូច្នេះនៅក្នុងប្រក្រតិទិនអ៊ីស្លាម ខែមាន ២៩ ឬ ៣០ ថ្ងៃ ផ្ទុយពីប្រក្រតិទិនសុរិយគតិដែលមាន ៣០ ថ្ងៃ ឬ ៣១ ថ្ងៃ។ តាមប្រក្រតិទិនអ៊ីស្លាមបានសេចក្ដីថាខែត្រូវនឹងរដូវផ្សេងៗពីឆ្នាំមួយទៅឆ្នាំមួយ។ នេះគឺព្រះគុណអល់ឡោះហ្ ﷻ ពីព្រោះយើងអាចកាន់សីលត្រណមនិងទៅធ្វើពិធីហាជ្ជក្នុងរដូវផ្សេងៗ (មិនមែនក្នុងរដូវដដែលៗ)។ បើឆ្នាំមួយរ៉ម៉ាដ្ធនចំរដូវក្ដៅ ថ្ងៃនឹងវែង (កាន់សីលត្រណមយូរ) ពីរបីឆ្នាំក្រោយមក បើរ៉ម៉ាដ្ធនចំរដូវរងា ថ្ងៃនឹងខ្លី (កាន់សីលត្រណមមិនយូរ)។

ដូចគ្នាដែរ ពេលបំពេញពិធីហាជ្ជក្នុងឆ្នាំក៏ផ្លាស់ប្ដូរដែរពេលដល់ខែស្ហុលហ៊ីជ្ជយ៉ាស្ហ ដូច្នេះបើពេលនេះមិនងាយស្រួលសម្រាប់បុគ្គលណាមួយទេ បុគ្គលនោះអាចដូរបានទៅឆ្នាំក្រោយៗ។

ឆ្នាំអ៊ីស្លាមចាប់ផ្ដើមដោយខែសោកសៅជាងគេ គឺខែមូហារ៉ម។ ក្នុងខែនេះយើងរំលឹកដល់ពលីកម្មរបស់អ៊ីមុាំហ៊្វសែន៍ صلوات الله عليه والسلام គ្រួសារព្រះអង្គ صلوات الله عليه والسلام និងបណ្ដាមិត្តព្រះអង្គ صلوات الله عليه والسلام ដែលបានបូជាជីវិតដើម្បីថែរក្សាសាសនាអ៊ីស្លាម យើងសិក្សាជីវប្រវត្តិរបស់ទុក្ករបុគ្គលទាំងនេះ។

យើងត្រូវប្ដេជ្ញាចិត្តសម្រាប់ឆ្នាំថ្មីក្នុងខែនេះ ដើម្បីចាប់ផ្ដើមឆ្នាំថ្មីជាមុស្លីមល្អ។

ខែអ៊ីស្លាមមាន៖

មូហារ៉ម (مُحَرَّم)

ស្វ៉ហ្វារ (صَفَر)
រ៉ប៊ីអ៊ុល-អៅវ៉ាល (رَبِيْعُ الأَوَّل)
រ៉ប៊ីអ៊ុល-អាខ្មៀរ (رَبِيْعُ الْآخِر)
យ៉ូម៉ាដា អាល់-អៅវ៉ាល់ (جَمَادِي الأَوَّل)
យ៉ូម៉ាដា អាល់-អាឃ៊ីរ៉ោះត៍ (جُمَادَى الْآخِرَة)
រ៉យ៉ាប់ (رَجَب)
ស្ហាក់បាន (شَعْبَان)
រ៉ម៉ាដន (رَمَضَان)
ស្ហៅវ៉ាល់ (شَوَّال)
ស៊ុល ក្អក់ដាស់ (ذُو الْقَعْدَة)
ស៊ុល ហ៊ីច្ចយ៉ាស់ (ذُو الْحِجَّة)

# លំហាត់ ២០

ធ្វើប្រក្រតិទិនខ្លួនឯង ។ ចូរកាត់ក្រដាសរឹងពីរកំណាត់គូរនៅខាងក្រោមនេះ រួចហើយយកកំណាត់ធំទៅសកក្នុងប្រឡោះនៅលើកំណាត់តូច ដើម្បីនឹងឲ្យឃើញឈ្មោះខែនៅក្នុងប្រឡោះតូចនេះ ។

មូហារ៉ម (مُحَرَّم)

ស្វហ្វារ (صَفَر)

រ៉ប៊ីអ៊ុល-អៅវ៉ាល (رَبِيْعُ الأَوّل)

រ៉ប៊ីអ៊ុល-អាខៀរ (رَبِيْعُ الْآخِر)

យូម៉ាដា អាល់-អៅវ៉ាល់ (جَمَادِي الأَوّل)

យូម៉ាដា អាល់-អាឃីរ៉ោះត៍ (جُمَادَى الْآخِرَة)

រ៉យ៉ាប់ (رَجَب)

ស្វាក់បាន (شَعْبَان)

រ៉ម៉ាដន (رَمَضَان)

ស្វៅវ៉ាល់ (شَوَّال)

ស៊ុល កក់ដាស់ (ذُو الْقَعْدَة)

ស៊ុល ហ៊ីចយ៉ាស់ (ذُو الْحِجَّة)

*Sources:*
imamia.org
shia974.fr
madressa.net